

# របាយការណ៍
## ប្រចាំឆ្នាំ ២០១៩

# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី
# SAHAKA MICROFINANCE INSTITUTION PLC

023 967 779 , 061 500 979 , 093 500 979 | info@sahakamfi.com | www.sahakamfi.com
ផ្ទះលេខ ២០៦ អឺ០អឺ១, ផ្លូវ ១៥៥, ក្រុមទី៥, ភូមិ១, សង្កាត់ ទូលទំពូងមួយ ខណ្ឌចំការមន រាជធានីភ្នំពេញ

# មាតិកា


## ១ សាររបស់ប្រធានក្រុមប្រឹក្សាភិបាល

សាររបស់ប្រធានក្រុមប្រឹក្សាភិបាល ១

## ២ អំពីសហការ

យើងជានរណា? ៣

ទស្សនវិស័យ បេសកកម្ម និងគុណតម្លៃស្នូល ៤

ផលិតផលរបស់យើង ៥

ចំណុចបន្លិចសំខាន់ៗនៃហិរញ្ញវត្ថុ ៦

ចំណុចបន្លិចសំខាន់ៗនៃប្រតិបត្តិការ ៧

ព័ត៌មានទូទៅ ៨

រចនាសម្ព័ន្ធ ៩

ក្រុមប្រឹក្សាភិបាល ១០

គណៈគ្រប់គ្រង ១១

## ៣ ការអភិវឌ្ឍន៍ឥតឈប់ឈរ

ការពង្រឹងសេវាកម្មអតិថិជន ១២

ការគ្រប់គ្រងធនធានមនុស្ស ១២

ដំណើរការនៃសវនកម្មផ្ទៃក្នុង ១៣

ការអភិវឌ្ឍន៍ការគ្រប់គ្រងហានិភ័យ ១៣

អភិបាលកិច្ច ១៤

## ៤ របាយការណ៍សវនករឯករាជ្យ

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ១៥

របាយការណ៍របស់សវនករឯករាជ្យ ១៩

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ២២

របាយការណ៍លទ្ធផលលម្អិត ២៣

របាយការណ៍ស្តីពីបម្រែបម្រួលមូលធន ២៤

របាយការណ៍លំហូរសាច់ប្រាក់ ២៦

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ២៨

# ១

# សាររបស់ប្រធានក្រុមប្រឹក្សាភិបាល

## សាររបស់ប្រធានក្រុមប្រឹក្សាភិបាល

*ជំនួសឲ្យក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងប្រចាំគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ខ្ញុំបាទមានសេចក្ដីរីករាយ នឹងបង្ហាញនូវរបាយការណ៍ប្រចាំឆ្នាំ ២០១៩ និងរបាយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្ម ប្រចាំឆ្នាំ គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ ទៅកាន់ភាគទុនិក និង ភាគីពាក់ព័ន្ធរបស់គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី។*



**លោក ប៊ុល វ៉ាន់នៀត**
**ប្រធានក្រុមប្រឹក្សាភិបាលនិងនាយកប្រតិបត្តិ**

*២០១៩ គឺជាឆ្នាំដែលយើងបានផ្ដោតសំខាន់លើការផ្លាស់ប្ដូរ។ វាគឺជាចំណុចមួយថ្មី ក្នុងដំណាក់កាលនៃការប្រកួតប្រជែងដ៏ខ្លាំងក្លា ជាមួយនឹងការបញ្ចប់ការរៀបចំកំណែទម្រង់រចនាសម្ព័ន្ធដ៏សំខាន់។*

### ក្រុមប្រឹក្សាភិបាល

ឆ្នាំ២០១៩ យើងមានការផ្លាស់ប្ដូរ សមាជិកក្រុមប្រឹក្សាភិបាលមួយរូប។ លោក តូស៊ីហ៊ីរ៉ូ មីយ៉ាអ៊ីឈិ ត្រូវបានជ្រើសរើស និងតែងតាំងជា អភិបាលឯករាជ្យថ្មី ប្រចាំក្រុមហ៊ុនចាប់តាំងពីថ្ងៃទី១ ខែ សីហា ឆ្នាំ ២០១៩។ ជំនួសឲ្យសមាជិកក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងទាំងអស់ យើងខ្ញុំសូមទទួលស្វាគមន៍យ៉ាងកក់ក្ដៅ ដែលលោកបានចូលជាផ្នែកមួយដ៏សំខាន់ នៃអភិបាលកិច្ចរបស់ក្រុមហ៊ុន។

### ការរីកចម្រើន នៃវិស័យហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា

ដោយសារតែសន្តិភាព សុវត្ថិភាព និង ស្ថេរភាពនៃការរីកចម្រើននៃសេដ្ឋកិច្ច យើងឃើញថាមានកំណើនកើនឡើង និងពង្រីកខ្លួនជាច្រើននៃស្ថាប័នហិរញ្ញវត្ថុ ដែលបច្ចុប្បន្ននេះ យើងឃើញថា ធនាគារពាណិជ្ជ មានចំនួន ៤៥ ធនាគារឯកទេសមានចំនួន ១៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមានចំនួន៧គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន៧៥និងក្រុមហ៊ុនភតិសន្យា មានចំនួន១៥។

### ក្រុមហ៊ុន

បន្តការរក្សាឲ្យបាននូវគុណភាពនៃសេវាកម្មទៅកាន់អតិថិជន យើងក៏បានយកចិត្តទុកដាក់ខ្លាំង លើគុណភាពនៃឥណទាន សម្លៀតឥណទាន លទ្ធផលនៃការអនុវត្ត និងលទ្ធិផលល្អដល់សង្គមផងដែរ នៅក្នុងឆ្នាំ ២០១៩។ ជាមួយនឹងអន្តរកាលដែលប្រទេសកម្ពុជាកំពុងស្ថិតក្នុងប្រទេសដែលមានប្រាក់ចំណូលកម្រិតទាបមធ្យម តម្រូវការនៃការប្រើប្រាស់ឥណទានច្រើនជាងមុនសម្រាប់អាជីវកម្មខ្នាតតូចនិងមធ្យម និងប្រជាពលរដ្ឋដែលមានប្រាក់ចំណូលមធ្យមក៏មានការកើនឡើងដែលជម្រុញឲ្យកំណើននៃឥណទានជាមធ្យម កើនឡើងរហូតជាង៥,២០០ដុល្លារ។

ជាចុងក្រោយនេះ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ភាគីពាក់ព័ន្ធទាំងអស់ ទាំងអតិថិជន អ្នកវិនិយោគ បញ្ញត្តិករ ធនាគារ និង ដៃគូហិរញ្ញវត្ថុ ទាំងក្នុងស្រុក និងក្រៅស្រុក សម្រាប់ការជឿជាក់ ការសហការ និងការគាំទ្រដល់ការរីកចម្រើនក្នុងឆ្នាំកន្លងមក។ ម្តងទៀតនេះខ្ញុំបាទក៏សូមអរគុណចំពោះ ក្រុមការងារ ក្នុងក្រុមប្រឹក្សាភិបាល សម្រាប់ការផ្តល់ជាអនុសាសន៍ និងការណែនាំ និងក្រុមការងារដែលស្ថិតក្នុងថ្នាក់គ្រប់គ្រង និងបុគ្គលិកទាំងអស់នៅទីនេះដែលបានដឹកនាំប្រកបដោយសមត្ថភាពនិងការតាំងចិត្តសម្រាប់ការងារដ៏ប្រសើរកន្លងមក។

## ទស្សនៈសម្រាប់ឆ្នាំ ២០២០

យោងតាមរបាយការណ៍នៃធនាគារជាតិនៃកម្ពុជា កំណើនសេដ្ឋកិច្ច របស់ប្រទេសកម្ពុជា នឹងរំពឹងថា អាចឈានដល់ជាង ៧% ក្នុងឆ្នាំ ២០២០ ដោយសារកំណើននៃការនាំចេញការវិនិ-យោគ ពីអ្នកវិនិយោគបរទេស ទេសចរណ៍ សំណង់ និង វិស័យអចលនទ្រព្យ។ ទោះបីជាយ៉ាងណាក៏ដោយ ឆ្នាំ២០២០ អាចនឹងជួបនូវឧបសគ្គ នៃកំណើនផងដែរ ដោយសារកត្តាខាងក្រៅមួយចំនួនដូចជាការធ្លាក់ចុះនៃសេដ្ឋកិច្ច របស់ប្រទេសចិន ដោយសារតែប្រទេស កម្ពុជាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយប្រទេសចិន។ ជាងនេះទៀតការអនុវត្តនូវគោលនយោបាយគាំពារនិយមអាចនឹងជះឥទ្ធិពលដល់ការនាំចេញ។ ជាចុងក្រោយនេះ មេរោគកូវីដ១៩ កំពុងរាតត្បាតជាសកល និងពិតជាជះឥទ្ធិពល ក្នុងរយៈពេលខ្លីទៅលើកំណើនសេដ្ឋកិច្ចដោយសារការធ្លាក់ចុះ នៃវិស័យ ទេសចរណ៍ ការកាត់បន្ថយនូវការផ្គត់ផ្គង់វត្ថុធាតុដើមសម្រាប់ វិស័យវាយនភណ្ឌ វិស័យសេវាកម្ម និង បដិសណ្ឋារកិច្ច។




បុល វ៉ាន់នៀត
ប្រធានក្រុមប្រឹក្សាភិបាល និង នាយកប្រតិបត្តិ
២៥ សីហា ២០២០

## សេចក្តីជូនដំណឹង!

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសហការ គីអិលស៊ី យើងខ្ញុំ
មានកិត្តិយសសូមជម្រាបជូនដល់អតិថិជន និង ភាគី
ពាក់ព័ន្ធទាំងអស់ឲ្យបានជ្រាបថា
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសហការ គីអិលស៊ី
គឺជាគ្រឹះស្ថានឯកជនសុទ្ធសាធ។

សូមអរគុណ!

*សូមតាមយើងខ្ញុំនៅលើគេហទំព័រហ្វេសប៊ុក*

# ២

## អំពីសហការ

## យើងជានរណា?

សហការ ត្រូវបានបង្កើតឡើងនៅក្នុងខែធ្នូ ឆ្នាំ២០១៥ ដោយវិនិយោគិន ២រូប ជាជនជាតិខ្មែរ និងជនជាតិជប៉ុន។ **សហការ** ទទួលបានអជ្ញាប័ណ្ណដែលទទួលស្គាល់ពីធនាគារជាតិ ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត នៅក្នុងខែ មេសា ឆ្នាំ ២០១៦ និងចាប់ផ្តើម ប្រតិបត្តិការអាជីវកម្មនៅក្នុងប្រទេសកម្ពុជាក្នុងការផ្តល់នូវ សេវាកម្មហិរញ្ញវត្ថុ តាមរយៈការផ្តល់កម្ចីទៅកាន់អតិថិជន។

រយៈពេលជាង ៤ឆ្នាំ នៃការប្រតិបត្តិអាជីវកម្ម **សហការ** បានផ្តល់សេវាកម្មជូនអតិថិជនជាច្រើន ទាំងក្នុងទីក្រុងភ្នំពេញ និង នៅតាមបណ្តាខេត្តមួយចំនួន។

ក្នុងឆ្នាំ ២០១៩ នេះ **សហការ** បានធ្វើការតាំងចិត្ត ក្នុងការប្រតិបត្តិ ទៅតាមបញ្ញត្តិរបស់ធនាគារជាតិ នៃកម្ពុជា ក្នុងការអនុវត្តន៍នូវស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ កម្ពុជា អន្តរជាតិ សម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SME)។

**ទីស្នាក់ការកណ្តាល**:
ផ្ទះលេខ ២០៦អឺ០អឺ១ ផ្លូវ ១៥៥ កែងផ្លូវ ៤៧០ សង្កាត់ទួលទំពូងទី១
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

| | |
|---|---|
| **ទូរសព្ទ** | ៖ +855 ( 0 )23 967 779 |
| អ៊ីម៉ែល | ៖ sahakamfi@sahakamfi.com |
| វេបសាយ | ៖ www.sahakamfi.com |
| ផ្នែកបម្រើអតិថិជន | ៖ +855 (0)61 500 979 / +855 (0)93 500 979 |
| អ៊ីម៉ែល | ៖ info@sahakamfi.com |

# ទស្សនវិស័យ បេសកកម្ម និង គុណតម្លៃស្នូល

## ទស្សនវិស័យ

ដើម្បីក្លាយជាស្ថាប័នដែលឈានមុខ ដែលអាចជួយបង្កើនជីវភាពរស់នៅរបស់ប្រជាជន សេដ្ឋកិច្ច និងសង្គម នៃប្រទេសកម្ពុជា ដោយបណ្តុះបណ្តាល ធនធានមនុស្សតាមរយៈការអប់រំ និងសេដ្ឋកិច្ច ដោយរក្សាកេរ្តិ៍ឈ្មោះរបស់ស្ថាប័ន គឺ (ធអសក)។

## បេសកកម្ម

គោលគំនិតអាជីវកម្មរបស់ពួកយើង គឺផ្តល់ជាសេវាកម្មហិរញ្ញវត្ថុ ជាមួយអាត្រាការប្រាក់សមរម្យដែលប្រជាជនអាចមានលទ្ធភាពប្រើប្រាស់សេវាកម្មរបស់ពួកយើងដើម្បីបង្កើនប្រាក់ចំណូល និងជីវភាពរស់នៅរបស់ប្រជាជន។

## គុណតម្លៃស្នូល



## ផលិតផលរបស់យើង

### Business Loan

កម្ចីដែលបានផ្តល់ ជូន សម្រាប់គាំទ្រ អាជីវកម្ម ធុនតូច ជាមួយនឹងការ ប្រើប្រាស់ ក្នុងគោល បំណង អាជីវកម្ម ជាក់ លាក់។

### Housing Loan

កម្ចីដែលផ្តល់ជូន អតិថិជន ដែលទិញ ឬ សាងសង់លំនៅដ្ឋាន របស់ពួកគេ។

### Car Loan

កម្ចីដែលផ្តល់ជូន អតិ-ថិជន សម្រាប់ការទិញ រថយន្ត។

### Education Loan

កម្ចីដែលផ្តល់ជូន សម្រាប់សិស្ស និស្សិត ក្នុងការបង់ចំណាយ ទាក់ទង នឹងថ្លៃសិក្សា ដូចជាថ្លៃ សាលា ឬ សម្ភារៈសិក្សា។

### Personal Loan

កម្ចីផ្តល់ជូន សម្រាប់ ការប្រើប្រាស់ផ្ទាល់ខ្លួន រាប់បញ្ចូលទាំង ចំណាយ ផ្គត់ផ្គង់ គ្រួសារនិងសម្រាប់ គោលបំណងផ្សេងៗ។



# ចំណុចបន្លិចសំខាន់ៗនៃហិរញ្ញវត្ថុ




| | ២០១៩ | ២០១៨ |
|---|---|---|
| នាចុងឆ្នាំនៃហិរញ្ញវត្ថុ ៣១ ធ្នូ | បានធ្វើសវនកម្មរួច | បង្ហាញសារឡើងវិញ |
| **សមតុល្យនៃស្ថានភាពហិរញ្ញវត្ថុ ( ដុល្លារអាមេរិក )** | | |
| ឥណទានសរុប ទៅកាន់អតិថជន | ៣,៨៩១,១៣៩ | ៥,៦៨០,៧៣១ |
| ដើមទុនសរុប | ៣៩២,៣០៧ | ១,២៩១,២១៧ |
| ទ្រព្យសកម្មសរុប | ៤,១៧១,៦៦៣ | ៧,០៦៥,៨៩៥ |
| **គណនីចំណេញខាត ( ដុល្លារអាមេរិក )** | | |
| ចំណូលសុទ្ធពីការប្រាក់ | ៣៦៤,៧០៨ | ៥៧៣,២៨៨ |
| កម្រៃសេវា និង ចំណូលផ្សេងៗសុទ្ធ | ៦៧,៨០៧ | ៥៤,៧៧០ |
| ប្រាក់ចំណេញសុទ្ធសាធ | (១,៣៩៨,៩១០) | (៣៣៥,៨៨៥) |
| ចំណាយពន្ធអប្បបរិមា | (៨,៣២០) | (១០,១៧០) |
| ឥណទានពន្ធលើប្រាក់ចំណូល | ៣១,០៨៦ | ៤១,០៩០ |

# ចំណុចបន្លិចសំខាន់ៗនៃប្រតិបត្តិការ




| | ២០១៩ | ២០១៨ |
|---|---:|---:|
| នាចុងឆ្នាំនៃប្រតិបត្តិការ ៣១ ធ្នូ | បានធ្វើសវនកម្មរួច | បង្ហាញសារឡើងវិញ |
| ចំនួនខេត្តប្រតិបត្តិការ | ២៤ | ១៧ |
| ចំនួនស្រុកប្រតិបត្តិការ | ១៣៨ | ៦៨ |
| ចំនួនឃុំប្រតិបត្តិការ | ៤៣០ | ១៥៩ |
| ចំនួនភូមិប្រតិបត្តិការ | ៧៩២ | ៣១០ |
| សាខាសរុប | ១ | ១ |
| ចំនួនបុគ្គលិកសរុប | ៣៩ | ៣៤ |
| ចំនួនអ្នកខ្ចីសរុប | ៧២៩ | ៥៩១ |
| អាត្រារក្សាអតិថិជន | ៣០% | ៥០% |
| សម្ពាធឥណទានសរុប | ៣,៨៩១,១៣៩ | ៥,៦៨០,៧៣១ |
| សម្ពាធឥណទាន/មន្ត្រីឥណទាន | ៦៤៨,៥២៣ | ៧១០,០៩១ |
| សម្ពាធឥណទាន/បុគ្គលិកសរុប | ១០៥,១៦៦ | ១៦៧,០៨០ |
| សម្ពាធឥណទានជាមធ្យម | ៥,៣៣៨ | ៩,៦១២ |
| ឥណទានហានិភ័យ (PAR%) | ១% | ៦% |

# ព័ត៌មានទូទៅ

ស្ថាប័ន
គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី

លេខវិញ្ញាបនបត្រ
០០០០៥៨៥៤ (Co. ៤៣៦១ E/២០១៥)

ការិយាល័យ
**ការិយាល័យកណ្តាល**
ផ្ទះលេខ២០៦ អឺ០អឺ១, ផ្លូវ ១៥៥ កែង ៤៧០, សង្កាត់ទួលទំពូងទី១,
ខណ្ឌចំការមន, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃអនុម័ត
ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦

លេខអាជ្ញាប័ណ្ណ
M.F-67

ទូរស័ព្ទទំនាក់ទំនង
(+៨៥៥) ២៣ ៩៦៧ ៧៧៩

សេវាទំនាក់ទំនងបន្ទាន់
(+៨៥៥) ៦១ ៥០០ ៧៧៩ | (+៨៥៥) ៩៣ ៥០០ ៧៧៩

គេហទំព័រ
www.sahakamfi.com

សារអេឡិចត្រូនិច
info@sahakamfi.com

*សូមតាមយើងខ្ញុំនៅលើគេហទំព័រហ្វេសប៊ុក*

# រចនាសម្ព័ន្ធ



គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហការ ភីអិលស៊ី
ម្ចាស់ភាគហ៊ុន
គណៈកម្មការសវនកម្មឯករាជ្យ
គណៈកម្មការតែងតាំង និងកម្រៃការ
ក្រុមប្រឹក្សាភិបាល
គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម
នាយកដ្ឋានគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម
ប្រធាននាយកប្រតិបត្តិ
គណៈកម្មការសវនកម្ម
នាយកដ្ឋានសវនកម្មផ្ទៃក្នុង
គណៈកម្មការឥណទាន
គណៈកម្មការអភិវឌ្ឍន៍យុទ្ធសាស្ត្រ និងគោលការណ៍
គណៈកម្មការវិន័យ និងបណ្តឹង
គណៈកម្មការពិសេស
ប្រធាននាយកប្រតិបត្តិការ
ប្រធាននាយកហិរញ្ញវត្ថុ
នាយកដ្ឋានឥណទាន
ផ្នែកផ្តល់កម្ចី
ផ្នែកគ្រប់គ្រងគុណភាពផលប័ត្រឥណទាន
នាយកដ្ឋានប្រតិបត្តិការ
ផ្នែករដ្ឋបាល
ផ្នែកទីផ្សារ
ផ្នែកបេឡា
នាយកដ្ឋានព័ត៌មានវិទ្យា
ផ្នែកសុវត្ថិភាពបណ្តាញព័ត៌មានវិទ្យា
ផ្នែកអភិវឌ្ឍន៍ប្រព័ន្ធធនាគារ
នាយកដ្ឋានហិរញ្ញវត្ថុ
ផ្នែកបៀវត្ស និងគណនេយ្យ
ផ្នែករតនាគារ និងរបាយការណ៍
ផ្នែកធនធានមនុស្ស

# ក្រុមប្រឹក្សាភិបាល



### លោក បុល វ៉ាន់ នៀត

*ប្រធានក្រុមប្រឹក្សាភិបាល និង នាយកប្រតិបត្តិ*

លោក បុល វ៉ាន់ នៀត ជានាយកប្រតិបត្តិប្រចាំគ្រឹះស្ថាន។ បន្ទាប់ពីបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រភាសាជប៉ុន ខាងផ្នែកអប់រំពីសកលវិទ្យាល័យភាសាបរទេស និងបានបញ្ចប់ថ្នាក់ទស្សនៈកិច្ចសិក្សាពីប្រទេសជប៉ុន លោកបានចូល បម្រើការងារ នៅក្នុងធនាគារ Bank of Tokyo-Mitsubishi UFJ Ltd (BTMU)។

លោក ក៏ ជានាយកប្រតិបត្តិ ប្រចាំក្រុមហ៊ុន នៀតអេដ្យូខេសិនណល អ៊ីនហ្វមេសិន សិន ធ័រ ខូអិលធីឌី និងជានាយកប្រតិបត្តិប្រចាំក្រុមហ៊ុន នីខេម ខូអិលធីឌី ផងដែរ។



### លោក តាកាហ៊ីរ៉ូ យ៉ាម៉ាស៊ីតាក់

*សមាជិកក្រុមប្រឹក្សាភិបាល និង នាយកប្រតិបត្តិហិរញ្ញវត្ថុ*

លោក តាកាហ៊ីរ៉ូ យ៉ាម៉ាស៊ីតាក់ ជានាយកហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន ហើយគាត់ក៏ជានាយកហិរញ្ញវត្ថុ ប្រចាំក្រុមហ៊ុន នៀតអេដ្យូខេសិនណល អ៊ីនហ្វមេសិន សិនធ័រ ខូអិល ធីឌី និងក្រុមហ៊ុន នីខេម ខូអិលធីឌី ផងដែរ។

បច្ចុប្បន្ននេះ លោកក៏មានតួនាទីជានាយកប្រតិបត្តិប្រចាំក្រុមហ៊ុន ស៊ីភីអូឌី ប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុ នៅក្នុងប្រទេសសឹង្ហបុរីផងដែរ។

លោក តាកាហ៊ីរ៉ូ មានបទពិសោធន៍ជាង ១៥ ឆ្នាំក្នុងវិស័យសេវាកម្មប្រឹក្សាយោបល់ខាងផ្នែកហិរញ្ញវត្ថុ។



### លោក តូស៊ីហ៊ីរ៉ូ មីយ៉ាអ៊ីឈិ

*ក្រុមប្រឹក្សាភិបាលឯករាជ្យ*

លោក តូស៊ីហ៊ីរ៉ូ មីយ៉ាអ៊ីឈិ ជាសមាជិកក្រុមប្រឹក្សាភិបាលឯករាជ្យប្រចាំគ្រឹះស្ថាន។ លោកក៏ជានាយកប្រតិបត្តិប្រចាំក្រុមហ៊ុន TM Pte. Ltd ដែលជាក្រុមហ៊ុនគ្រប់គ្រងទ្រព្យសម្បត្តិឯកជន និងវិនិយោគ ហើយក៏ជានាយកប្រតិបត្តិប្រចាំក្រុមហ៊ុន Miyauchi Electric Engineering Co., LTD នៅក្នុងប្រទេសជប៉ុនផងដែរ។

លោក តូស៊ីហ៊ីរ៉ូ មានបទពិសោធន៍ជាច្រើនឆ្នាំក្នុងការគ្រប់គ្រងអាជីវកម្ម និងហិរញ្ញវត្ថុនៅក្នុងប្រទេសជប៉ុន។

## គណៈគ្រប់គ្រង



**លោក ស៊ុម ស៊ីណាត**
*ប្រធាននាយកប្រតិបត្តិការ*

លោក ស៊ុម ស៊ីណាត ជានាយកប្រតិបត្តិការប្រចាំគ្រឹះស្ថាន។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម នៅក្នុងឆ្នាំ ២០០៧បរិញ្ញាប័ត្រផ្នែកគ្រប់គ្រងអាជីវកម្មនិងបរិញ្ញាប័ត្ររងផ្នែកគណនេយ្យនៅក្នុងឆ្នាំ២០០៥។ លោក មានបទពិសោធន៍ជាង ១៦ឆ្នាំនៅក្នុងវិស័យ មីក្រូហិរញ្ញវត្ថុ ជាមួយនឹងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ទាំងទទួលប្រាក់បញ្ញើ និង មិនទទួលប្រាក់បញ្ញើនៅក្នុងប្រទេសកម្ពុជា។



**លោក ប៉ុល វុទ្ធីរីថ**
*ប្រធានគ្រប់គ្រងឥណទាន*

លោក ប៉ុល វុទ្ធីរីថ ជាប្រធានគ្រប់គ្រងឥណទានប្រចាំគ្រឹះស្ថាន។ លោកកំពុងបន្តយកបរិញ្ញាប័ត្រផ្នែកច្បាប់ បន្ទាប់ពីបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រក្នុងជំនាញគណនេយ្យ ក្នុងឆ្នាំ ២០០៦។ លោក វុទ្ធីរីថ មានបទពិសោធន៍ជាង ១៤ ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើរ និងធនាគានៅក្នុងប្រទេសកម្ពុជា។



**លោក សេង ចាន់ធឿន**
*ប្រធានគ្រប់គ្រងហិរញ្ញវត្ថុ*

លោក សេង ចាន់ធឿន ជាប្រធានគ្រប់គ្រងហិរញ្ញវត្ថុប្រចាំគ្រឹះស្ថាន។ លោកកំពុងបន្តយកជំនាញ គណនេយ្យករសាធារណៈដែលសិក្សាជាមួយកម្មវិធី ACCA។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រក្នុងជំនាញគណនេយ្យ ក្នុងឆ្នាំ ២០០៤ និង បរិញ្ញាប័ត្ររង ផ្នែកលក់ និងទីផ្សារ ក្នុងឆ្នាំ ២០០១។ លោកមានបទពិសោធន៍ជាង ១៥ឆ្នាំក្នុងផ្នែកហិរញ្ញវត្ថុ ជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល និង គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ។



**កញ្ញា ភឿក សម្ភស្ស**
*ប្រធានគ្រប់គ្រងផ្នែកធនធានមនុស្ស និងរដ្ឋបាល*

កញ្ញា ភឿក សម្ភស្ស ជាប្រធានគ្រប់គ្រងធនធានមនុស្ស និងរដ្ឋបាល។ កញ្ញាបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ ក្នុងជំនាញគណនេយ្យក្នុងឆ្នាំ ២០១១។ កញ្ញា មានបទពិសោធន៍ជាង ៧ឆ្នាំក្នុងជាគណនេយ្យករ និងរដ្ឋបាល ជាមួយនឹងវិស័យឯកជនជាច្រើន ដូចជាក្រុមហ៊ុនលក់ទំនិញ សណ្ឋាគារ និង គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ។



**លោក ជី ឡុងហេង**
*ប្រធានគ្រប់គ្រងសវនកម្មផ្ទៃក្នុង*

លោក ជី ឡុងហេង ជាប្រធានគ្រប់គ្រងសវនកម្មផ្ទៃក្នុងប្រចាំគ្រឹះស្ថាន។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុនៅក្នុងឆ្នាំ ២០១៩ និង ថ្នាក់បរិញ្ញាប័ត្រផ្នែកគណនេយ្យក្នុងឆ្នាំ ២០១២។ លោកមានបទពិសោធន៍ជាង ៦ឆ្នាំក្នុងផ្នែកហិរញ្ញវត្ថុ គណនេយ្យ និង សវនកម្ម ជាមួយនឹង គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុទាំងទទួលប្រាក់បញ្ញើ និងមិនទទួលប្រាក់បញ្ញើ និងក្រុមហ៊ុនភាគីសន្យានៅក្នុងប្រទេសកម្ពុជា។



**លោក នៅ វិច្ឆិកា**
*មន្ត្រីជាន់ខ្ពស់ ផ្នែកគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម*

លោក នៅ វិច្ឆិកា ជាមន្ត្រីជាន់ខ្ពស់ផ្នែកគ្រប់គ្រងហានិភ័យ និងប្រតិបត្តិ។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រជំនាញ សេដ្ឋកិច្ច ក្នុងឆ្នាំ២០១០ និងថ្នាក់អនុបណ្ឌិត ផ្នែកគ្រប់គ្រងទូទៅ ក្នុងឆ្នាំ ២០១៥។ លោកមានបទពិសោធន៍ជាង ៩ឆ្នាំ ជាអ្នកសម្របសម្រួលផ្នែកទីផ្សាររយៈពេល ៤ឆ្នាំ ហើយបានផ្លាស់ប្តូរមកវិស័យធនាគារ និងហិរញ្ញវត្ថុចាប់តាំងពីឆ្នាំ ២០១៤។

# ៣

# ការអភិវឌ្ឍន៍ឥតឈប់ឈរ

## ការពង្រឹងសេវាកម្មអតិថិជន



កញ្ញា គង់ ស្រីខួច
*ប្រធានបេឡាករ*

ការតាំងចិត្ត ដ៏ខ្លាំងក្លារបស់យើង គឺការផ្តល់ឲ្យអតិថិជនរបស់យើង នូវភាពប្រសើរ និង ប្រសិទ្ធភាពនៃសេវាកម្មខាងផ្នែកហិរញ្ញវត្ថុ។ យើងខ្ញុំ **សហការ** បានបង្កើតនូវជំហ៊ានថ្មីមួយទៀត ដោយផ្តល់លទ្ធភាពដល់អតិថិជនក្នុងការទូទាត់ឥណទានរបស់ពួកគេតាមរយៈការផ្ទេរប្រាក់តាមប្រព័ន្ធធនាគារ និង ការផ្ទេរតាមបញ្ជរ វីង។

ក្នុងឆ្នាំ ២០១៩ យើងបានរក្សានូវការសន្យាក្នុងការពង្រីកវិសាលភាពការងារ និងបម្រើសេវាកម្មជូនអតិថិជនយើង ដែលមានជាសំនួរតាមរយៈបណ្តាញទំនាក់ទំនងសង្គម ដូចជា គេហទំព័រ facebook និង មជ្ឈមណ្ឌលក្នុងការបម្រើសេវាអតិថិជន។

ក្រៅពីសេវាកម្មទូទាត់នៅបញ្ជរបេឡា យើងបានបន្ថែមនូវការទទួលទូទាត់តាមរយៈប្រព័ន្ធ ធនាគារ និង ការផ្ទេរជាមួយភ្នាក់ងារ វីង។ អតិថិជនរបស់យើងមានការរីករាយជាខ្លាំងដោយសារពួកគេអាចផ្ញើប្រាក់សម្រាប់ទូទាត់ឥណទានតាមរយៈភ្នាក់ងារ វីង ដែលនៅជិតពួកគេបំផុត។

ជាចុងក្រោយនេះ យើងមិនភ្លេចអំពីការដោះស្រាយបណ្តឹងអតិថិជន និងការផ្តល់យោបល់កែលម្អពីអតិថិជនរបស់យើងឡើយ។ សេវាកម្មផ្តល់ព័ត៌មានទាន់ហេតុការណ៍ និងសេវាកម្មដោះស្រាយបណ្តឹងអតិថិជន នៅតែបន្តការអភិវឌ្ឍន៍ឥតឈប់ឈរ តាមរយៈការកែសម្រួលនីតិវិធី និង បទដ្ឋានក្នុងការឆ្លើយតប ដែលជាតម្រូវការរបស់អតិថិជន។ គណៈកម្មការដោះស្រាយបណ្តឹងបានធ្វើការយ៉ាងជិតស្និទជាមួយនឹងភាគីពាក់ព័ន្ធ ទាំងខាងក្នុង និងខាងក្រៅ ដើម្បីស្វែងរកដំណោះស្រាយសម្រាប់អតិថិជនរបស់យើង។

## ការគ្រប់គ្រងធនធានមនុស្ស

បុគ្គលិក គឺជាទ្រព្យរបស់យើង ប្រសិនបើគ្មានពួកគាត់ទេ នោះយើងនឹងមិនអាចផ្តល់នូវសេវាកម្មប្រកបដោយគុណភាពទៅកាន់អតិថិជនរបស់យើងបានឡើយ។ សហការ បានខិតខំប្រឹងប្រែង និងចំណាយពេលវេលាយ៉ាងច្រើនក្នុងឆ្នាំនេះ ដើម្បីអភិវឌ្ឍចំណេះដឹង និងជំនាញបន្ថែមដល់បុគ្គលិក ទៅលើ ផលិតផល និងសេវាកម្មរបស់យើង។

ក្នុងឆ្នាំ២០១៩ យើងបានបង្កើតនូវប្រព័ន្ធក្នុងការជម្រុញការអភិវឌ្ឍន៍សមត្ថភាព ដែលរួមបញ្ចូលទាំងកម្មវិធីបណ្តុះបណ្តាល និង ប្រព័ន្ធផ្តល់ការងារ ។ យើងក៍បានបង្កើតនូវបរិយាកាសធ្វើការងារប្រកបដោយភាពស្និទ្ធស្នាលដែលឆ្លើយតបទៅនឹងភាពខុសគ្នានៃនិយោជិករបស់យើង ខណៈពេលដែលកំពុងលើកកម្ពស់ការគ្រប់គ្រងមានលក្ខណៈចម្រុះ។

យើងមានបំណងឲ្យមាននូវការរីកចម្រើនដ៏មានស្ថេរភាព តាមរយៈការពង្រឹងនូវការអភិវឌ្ឍន៍ធនធានមនុស្ស ដែលជាបញ្ហាចម្បងរបស់អ្នកគ្រប់គ្រង។



កញ្ញា ភឿក សម្ផស្ស
*ប្រធានគ្រប់គ្រងធនធានមនុស្ស និងរដ្ឋបាល*

## ដំណើរការនៃសវនកម្មផ្ទៃក្នុង



លោក ជី ឡុងហេង
*ប្រធានគ្រប់គ្រងសវនកម្មផ្ទៃក្នុង*

*ត្រូវបានទទួលស្គាល់ដោយ ធនាគារជាតិនៃកម្ពុជា*

ចំណុចខ្ពស់បំផុតចំពោះកាតព្វកិច្ចនៃការប្រតិបត្តិ នាយកដ្ឋានសវនកម្ម របស់សហការ បានធ្វើការ ចុះសវនកម្មចំនួន ៤ ដង ទៅតាមកាលវិភាគក្នុងឆ្នាំ ២០១៩ ដើម្បីស្វាបស្ទង់គុណភាពនៃសេវាកម្មហិរញ្ញវត្ថុ។ នេះគឺជាបទដ្ឋានអប្បបរិមា និងជានីតិវិធី ដើម្បីធានានូវ ភាពថ្លៃថ្នូរនៃប្រតិបត្តិការ នៅក្នុងកម្រិតស្ថាប័ន ក៏ដូចជាកម្រិតបុគ្គលិក។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានធ្វើបច្ចុប្បន្នភាព ទៅលើនីតិវិធី ដើម្បីធ្វើការកត់សម្គាល់ជាមួយនឹងការផ្លាស់ប្តូរក្នុងស្ថាប័ន និងបានរៀបចំជាគោលការណ៍ណែនាំ ដូចជា ការពិព័ណនា អំពីនីតិវិធី នៃការសិក្សាអាជីវកម្មគំនូសបំព្រួញនៃការវិភាគលើហានិភ័យ និងការវាយតម្លៃលើការរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីធានានូវការកំណត់ដ៏សមរម្យនូវកម្មវត្ថុ និងវិសាលភាពនៃសវនកម្មដែលមានទំនាក់ទំនងជាមួយនិងកម្រិតនៃហានិភ័យ។ ទន្ទឹមនឹងនេះបច្ចេកទេសនៃការធ្វើសវនកម្មផ្សេងៗជាច្រើន ការវិភាគលើនិន្នាការ និងការស្វែងរកទិន្នន័យផ្សេងៗក៏ត្រូវបានប្រើប្រាស់ក្នុងការរៀបចំផែនការណ៍សវនកម្ម។

## ការអភិវឌ្ឍន៍ការគ្រប់គ្រងហានិភ័យ

វាជាការតាំងចិត្តរបស់យើង ដែលតែងតែយកចិត្តទុកដាក់ខ្ពស់ ក្នុងការប្រតិបត្តិជាមួយនឹងបញ្ញត្តិ ដែលរួមមានបញ្ញត្តិ ក្នុងការប្រឆាំងការលាងសម្អាតសាច់ប្រាក់ និងការផ្តល់ហិរញ្ញប្បទានភេរវកម្ម (AML/CFT) ក៏ដូចជា ច្បាប់ដែលបានចែងមួយចំនួនដែលតម្រូវឲ្យអនុវត្ត។

គណៈគ្រប់គ្រង របស់ **សហការ** មានឆន្ទៈ និងការតាំងចិត្តយ៉ាងមោះមុត ក្នុងការប្រតិបត្តិ និងវិនិយោគលើការអភិវឌ្ឍន៍ធនធានមនុស្សនិងបណ្តុះបណ្តាលសម្រាប់នាយកដ្ឋានប្រតិបត្តិ ដែលជាការត្រៀមទុកជាមុន និងជាការអនុវត្តន៍ និងរក្សាគោលការណ៍ក្របខណ្ឌ និង នីតិវិធី ដើម្បីតាមដានឲ្យសមស្របទៅតាមកាតព្វកិច្ចដូចមានចែងក្នុងបញ្ញត្តិ។

ដូចមានចែងក្នុងច្បាប់ និងប្រកាសរបស់ធនាគារជាតិនៃកម្ពុជា **សហការ** បានអនុវត្តលើការប្រើប្រាស់ស្តង់របាយការណ៍ហិរញ្ញវត្ថុ កម្ពុជា អន្តរជាតិ សម្រាប់សហគ្រាសធុនតូច និងមធ្យម (CIFRS for SME)។

នៅចុងឆ្នាំ២០១៨រហូតចូលដើមឆ្នាំ២០១៩យើងត្រូវបានចុះត្រួតពិនិត្យពីធនាគារជាតិនៃកម្ពុជា ហើយជារួមយើងទទួលបានលទ្ធផលគួរជាទីគាប់ប្រសើរ។ នេះគឺជាទីគោល ដ៏សំខាន់មួយរបស់យើង សម្រាប់ការអភិវឌ្ឍន៍ឲ្យកាត់តែប្រសើរនៅថ្ងៃខាងមុខ។



*លោក នៅ វិច្ចិកា*
*មន្ត្រីជាន់ខ្ពស់ផ្នែកគ្រប់គ្រងហានិភ័យ និងប្រតិបត្តិតាម*

*ត្រូវបានទទួលស្គាល់ដោយធនាគារជាតិនៃកម្ពុជា*

## អភិបាលកិច្ច

ទន្ទឹមនិងការតាំងចិត្ត ដើម្បីភាពរីកចម្រើននៅក្នុងពេលអនាគតខាងមុខ **សហការ** បានរៀបចំនូវប្រព័ន្ធអភិបាលគ្រប់គ្រង ដើម្បីអនុវត្ត សម្រាប់ធ្វើការសម្រេចចិត្ត និងបង្កើននូវតម្លាភាពនៃការគ្រប់គ្រង។ យោងតាមបញ្ញត្តិ គ្រឹះស្ថានបានបង្កើតនូវគណៈកម្មការបញ្ញត្តិចំនួនពីរ ក្រៅពីគណៈកម្មការសំខាន់ៗផ្សេងទៀត គឺ គណៈកម្មការតែងតាំងនិងកម្រៃការ និងគណៈកម្មការសវនកម្ម។ ក្នុងការបង្កើតនេះ គ្រឹះស្ថានបានដាក់ជាប្រព័ន្ធ និងរាយការណ៍ទៅកាន់ក្រុមប្រឹក្សាភិបាល ហើយគណៈកម្មការទាំងពីរនេះ អាចផ្តល់នូវត្រួតពិនិត្យ ដ៏សមស្របលើការគ្រប់គ្រង។

**គណៈកម្មការឥណទាន**

គណៈកម្មការនេះត្រូវបានបង្កើតឡើង ដើម្បីធ្វើការត្រួតពិនិត្យនិងទទួលរបាយការណ៍ ដែលចាំចាំបាច់ ពីផ្នែកនៃគណៈគ្រប់គ្រងផ្សេងដើម្បីធ្វើការប៉ាន់ស្មាន និងគ្រប់គ្រងហានិភ័យ ឥណទាន។ គណៈកម្មការមានតួនាទីក្នុងការចាត់ចែង និងធ្វើការគ្រប់គ្រងលើប្រសិទ្ធភាព និងប្រតិបត្តិទៅតាមគោលនយោបាយឥណទាន តាមរយៈការត្រួតពិនិត្យលើនីតិវិធី ការទទួលរបាយការណ៍ និងព័ត៌មានផ្សេងៗដែលមានសារសំខាន់ រួមមាន ការឲ្យពិន្ទុលើ គុណភាពនៃឥណទាន ការត្រួតពិនិត្យលើដំណើរការឥណទាន ការគាំទ្រដល់ការធ្វើសវនកម្មផ្ទៃក្នុង និងសវនកម្មឯករាជ្យទៅលើដំណើរការឥណទាន ការជួបភាពចៃដន្យនៃបញ្ហាថ្មី ការស្នើជាញឹកញយនូវករណីលើកលែងខុសពីគោលការណ៍ មុខងារក្នុងការត្រួតពិនិត្យឥណទាន និងនីតិវិធីក្នុងការចាត់ថ្នាក់កម្រិតសំពៀតឥណទាន។ គណៈកម្មការក៏មានតួនាទីក្នុងការត្រួតពិនិត្យ សមត្ថភាពការងារ និងគុណភាព នៃឥណទានតាមរយៈការពិនិត្យលើគំរូឥណទានដែលបានជ្រើសរើស និងព័ត៌មានដ៏សមរម្យ រួមបញ្ចូលទាំងការចាត់ថ្នាក់ឥណទាន និងឥណទានមិនដំណើរការ។

**គណៈកម្មការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិ**

គណៈកម្មការនេះជាអ្នករៀបចំនូវប្រព័ន្ធគ្រប់គ្រងហានិភ័យ និងគោលការប្រតិបត្តិ និង រៀបចំប្រព័ន្ធប្រតិបត្តិ តាមមូលដ្ឋានផែនការ AML/CFT និងជាអ្នកគ្រប់គ្រងការពិភាក្សាផ្តល់របាយការណ៍ ទាក់ទងទៅនឹងកម្មវិធី លើបញ្ហាទាំងនេះ។

**គណៈកម្មការសវនកម្ម**

គណៈកម្មការនេះ រៀបចំការធ្វើសវនកម្ម និងរបាយការណ៍សវនកម្ម លើការប្រតិបត្តិរបស់ មន្ត្រី និងនាយកគ្រប់គ្រង។ ក្រៅពីនេះ គណៈកម្មការមានសិទ្ធិ សម្រេចនិងស្នើ តែងតាំង ឬបញ្ឈប់ សវនករឯករាជ្យ ទៅកាន់កិច្ចប្រជុំភាគទុនិកប្រចាំឆ្នាំ។

**គណៈកម្មការតែងតាំង និងកម្រៃការ**

គណៈកម្មការនេះនឹងកំណត់លក្ខខណ្ឌពាក់ព័ន្ធនឹងការតែងតាំង ឬបញ្ឈប់នាយកគ្រប់គ្រង។ បន្ថែមលើនេះទៀត គណៈកម្មការមានសិទ្ធិក្នុងការកំណត់ និងស្នើ តែងតាំង ឬ បញ្ឈប់ នាយកគ្រប់គ្រង ទៅកាន់កិច្ចប្រជុំភាគទុនិកប្រចាំឆ្នាំ។

**គណៈក្រុមប្រឹក្សាភិបាល**

គណៈក្រុមប្រឹក្សាភិបាលមាន បី រូប។ ដែលក្នុងនោះ ពីររូបក្នុងចំណោមពួកគេបានបំពេញ មុខងារជានាយកគ្រប់គ្រង និងមួយរូបទៀត ជាអភិបាលឯករាជ្យ។

**គណៈកម្មការពិសេស**

គណៈកម្មការពិសេសនេះ នឹងជាជំនួយ ដល់គណៈគ្រប់គ្រង ក្នុងការពិភាក្សាទៅលើ តម្រូវការជាក់លាក់។

# ៤

# របាយការណ៍សវនករឯករាជ្យ

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមធ្វើការបង្ហាញ ជូននូវរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនដោយភ្ជាប់ជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសហការ ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019។

### សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ និងសេវាកម្មហិរញ្ញវត្ថុពាក់ព័ន្ធផ្សេងទៀត ដែលមាននៅក្នុងវិសាលភាពអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការប្រែប្រួលជាសារវន្តទៅលើសកម្មភាពចម្បងនៅក្នុងការិយបរិច្ឆេទនោះទេ។

### លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 មានដូចខាងក្រោម៖

| | 2019 | | 2018 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) |
| ប្រាក់ខាតមុនដកពន្ធ | (1,429,996) | (5,794,344) | (376,975) | (1,524,863) |
| ឥណទានពន្ធលើប្រាក់ចំណេញ | 31,086 | 125,960 | 41,090 | (166,209) |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | (1,398,910) | (5,668,384) | (335,885) | (1,358,654) |

### ភាគលាភ

ពុំមានភាគលាភណាត្រូវបានប្រកាស ឬត្រូវបានបង់ ហើយក្រុមប្រឹក្សាភិបាលក៏ពុំបានផ្តល់ជាអនុសាសន៍ឲ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនេះទេ។

### ដើមទុន

ដើមទុនចុះបញ្ជី និង ដែលបានបង់របស់ក្រុមហ៊ុននាថ្ងៃ ទី31 ខែធ្នូ ឆ្នាំ2019 មានចំនួន 1,800,000 ដុល្លារអាមេរិក (2018: 1,800,000 ដុល្លារអាមេរិក) ដែលក្នុងមួយភាគហ៊ុនមានតម្លៃស្មើនឹង 1ដុល្លារអាមេរិក។
នៅថ្ងៃទី17 ខែកុម្ភៈ ឆ្នាំ2020 ក្រុមហ៊ុនបានទទួលការអនុម័តពីក្រសួងពាណិជ្ជកម្ម ចំពោះការស្នើសុំនៅថ្ងៃទី18 ខែតុលា ឆ្នាំ2019 ដើម្បីបង្កើនដើមទុនរបស់ក្រុមហ៊ុនពី 1,800,000 ដុល្លារអាមេរិក ទៅ2,300,000ដុល្លារអាមេរិក តាមរយៈការបែងចែកភាគហ៊ុនបន្ថែមចំនួន 500,000 ដែលមានតម្លៃ 1 ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន។

រចនាសម្ព័ន្ធភាគហ៊ុននេះបានផ្លាស់ប្តូរដោយការដាក់បន្ថែមភាគហ៊ុនចំនួន 500,000 ហ៊ុន។

លក្ខន្តិកៈក្រុមហ៊ុន ដែលត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរខាងលើត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី17 ខែកុម្ភៈ ឆ្នាំ2020។

### ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទានអាក្រក់ និងឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការ ដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា វិធានការទាក់ទងនឹងការលុបចោលនូវ ឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយមានការជឿជាក់ថាមិនមានឥណទានអាក្រក់ និងសំវិធានធនត្រូវបានធ្វើឡើងសម្រាប់ឥណទានជាប់សង្ស័យ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយដែលអាចនឹងបណ្តាលឲ្យចំនួននៃការលុបបំបាត់ចោលឥណទានអាក្រក់ ឬចំនួននៃការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានចំនួនខ្វះខាតជាសារវន្តនោះឡើយ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តទាំងអស់ ក្រៅពីបំណុលដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ហើយដែ លទំនងជាមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលរំពឹងទុកថានឹងអាចប្រមូលបានជាក់ស្តែង។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗ

នាថ្ងៃការិយបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(ក) ការប្រែប្រួលទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុនដែលកើតមានឡើងដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាមួយចាប់តាំងពីដំណាច់ឆ្នាំឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។

ក្រុមប្រឹក្សាភិបាលមានមតិថា ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវបំពេញ ឬអាច នឹងត្រូវបំពេញក្នុងរយៈពេល 12 ខែបន្ទាប់ពីចុងការិយបរិច្ឆេទនេះ ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្ត ដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទដល់ថ្ងៃចេញ របាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍

ពុំមានព្រឹត្តិការណ៍សារវន្តកើតឡើងក្រោយកាលបរិច្ឆេទរាយការណ៍ ដែលតម្រូវឲ្យមានការលាតត្រដាង ឬនិយ័តភាព ក្រៅពីព្រឹត្តិការណ៍ដែលបានលាតត្រដាងរួចហើយនៅក្នុងកំណត់សម្គាល់ដែលភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ។

## សមាជិកក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលបម្រើការនៅក្នុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះមានរាយនាមដូចខាងក្រោម៖

| | |
|---|---|
| លោក បុល វ៉ាន់នៀត | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Yamashita Takahiro | អភិបាល |
| លោក Miyauchi Toshihiro | អភិបាលឯករាជ្យ |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

មិនថានៅចុងការិយបរិច្ឆេទ ឬនៅក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះ គឺមិនមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាង ដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះអាចផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាល ណាម្នាក់ឲ្យទទួលបាននូវអត្ថប្រយោជន៍ តាមមធ្យោបាយផ្សេងៗ ដូចជាការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់កុម្រហ៊ុន ឬសាជីវកម្មដទៃ។ ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុនៃឆ្នាំកន្លងទៅ ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរាប់បញ្ចូលក្នុងចំនួនសរុបនៃឯកត្តជនដែលបានទទួល ឬកំណត់និងអាចទទួលបានដោយក្រុមប្រឹក្សាភិបាល) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុនជាមួយក្រុមប្រឹក្សាភិបាល ឬដោយក្រុមហ៊ុនផ្សេងដែលមានក្រុមប្រឹក្សាភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនផ្សេងដែលមានក្រុមប្រឹក្សាភិបាលជាសមាជិកនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុច្រើនជាងអ្វីត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈកិច្ចធ្វើការអះអាង និងអនុវត្តន៍ដូចខាងក្រោម ៖

(ក) អនុម័តនូវគោលការណ៍គណនេយ្យសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះប្រកបដោយសង្គតិភាព។

(ខ) អនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម") ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះដើម្បីបង្ហាញពីភាពពិត និងត្រឹមត្រូវ គឺត្រូវតែបង្ហាញ និងពន្យល់ឲ្យបានច្បាស់លាស់ និងកំណត់បរិមាណឲ្យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(គ) ត្រួតពិនិត្យប្រព័ន្ធដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព។

(ឃ) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនចំពោះការបន្តនិរន្តរភាពអាជីវកម្មទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាព អាជីវកម្ម និងប្រើប្រាស់មូលដ្ឋាន និរន្តរភាពនៃស្តង់ដារនៃស្តង់ដារគណនេយ្យ លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងចង់ជម្រះបញ្ជីក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចសំខាន់ៗទាំងឡាយដែលប៉ះពាល់ដល់សកម្មភាព ប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការដូចដែលបានរាយការណ៍ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុន។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំតំណាងឲ្យក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសហការ ភីអិលស៊ី សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលភ្ជាប់មកជាមួយដូចបានបង្ហាញនៅទំព័រទី 10 ដល់ 63 ដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម")។

ចុះហត្ថលេខាដោយអនុលោមទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល




លោក បុល វ៉ាន់នៀត
*ប្រធានក្រុមប្រឹក្សាភិបាល*
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី25 ខែសីហា ឆ្នាំ 2020

# របាយការណ៍របស់សវនករឯករាជ្យជូនចំពោះភាគទុនិក
# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសហការ ភីអិលស៊ី

## មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសហការ ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ ផ្សេងៗទៀតដែលបានបង្ហាញនៅទំព័រក្រោយៗ។ជាមតិរបស់យើងខ្ញុំរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវភាពត្រឹមត្រូវក្នុងកម្រិតជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម")។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានឯករាជ្យភាពពីក្រុមហ៊ុនតាមគោលការណ៍នៃ "ក្រមសីលធម៌សម្រាប់គណនេយ្យករជំនាញវិជ្ជាជីវៈ" ហៅកាត់ថា (IESBA Code) ដែលដាក់ចេញដោយគណៈក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យ បន្ថែមពីនេះទៀត យើងខ្ញុំក៏បានបំពេញតាមក្របខ័ណ្ឌទំនួលខុសត្រូវក្រមសីលធម៌ផ្សេងៗ ស្របតាម IESBA Code។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 ត្រូវបាន ធ្វើសវនកម្មដោយសវនករផ្សេងទៀត ដែលបានបញ្ចេញមតិសវនកម្មនៅថ្ងៃទី29 ខែឧសភា ឆ្នាំ2019 ថា របាយការណ៍នោះមានភាពត្រឹមត្រូវ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រងមានការទទួលខុសត្រូវលើព័ត៌មានផ្សេងៗទៀត។ ព័ត៌មានផ្សេងៗទៀតដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍របស់សវនករ មានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល នៅទំព័រទី 1 ដល់ទី 5 និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដែលរំពឹងថានឹងរួចរាល់បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។

មតិរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់ព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំក៏មិនបានបញ្ចេញការសន្និដ្ឋានជាក់លាក់បន្ថែមលើនេះដែរ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺត្រូវអានព័ត៌មានផ្សេងៗហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត ឬទេ។

ប្រសិនបើការមានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះអាចឲ្យយើងខ្ញុំសន្និដ្ឋានថាមានកំហុស ឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវ លើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

- ធ្វើការកំណត់និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈ គ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្ត ដែលកើតឡើងដោយសារតែការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។

- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។

- ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យ ដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។

- ធ្វើការសន្និដ្ឋានលើភាពសមស្រប នៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ជាសារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការ

- លាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់នូវនិរន្តរភាពនៃអាជីវកម្ម។

  វាយតម្លៃលើការបង្ហាញ រចនាសម្ព័ន្ធ និងមាតិកាទូទៅនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាននិងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

តំណាងក្រុមហ៊ុន **អេចអឌីភី & អឺសូស៊ីអេត ខូ អិលធីឌី**




៣៧ ដារ៉ា

*នាយកសវនករ*

រាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី25 ខែសីហា ឆ្នាំ 2020

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩

| | កំណត់សម្គាល់ | 2019 | | 2018 | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទ្រព្យសកម្ម | | | (កំណត់សម្គាល់ 2.4) | | (កំណត់សម្គាល់ 2.4) |
| សាច់ប្រាក់ក្នុងដៃ | 6 | 49,956 | 203,571 | 99,748 | 400,787 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | 7 | 121,372 | 494,591 | 100,805 | 405,034 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ | 8 | 432,097 | 1,760,795 | 1,323,486 | 5,317,767 |
| ឥណទានផ្តល់ដល់អតិថិជនសុទ្ធ | 9 | 3,336,883 | 13,597,798 | 5,318,144 | 21,368,303 |
| ទ្រព្យសកម្មផ្សេងៗ | 10 | 38,197 | 155,653 | 23,594 | 94,801 |
| ទ្រព្យ និងបរិក្ខារ | 11 | 120,781 | 492,183 | 157,551 | 633,040 |
| ទ្រព្យសកម្មអរូបី | 12 | 201 | 819 | 1,477 | 5,935 |
| ពន្ធពន្យារជាទ្រព្យសកម្ម | 13(ក) | 72,176 | 294,117 | 41,090 | 165,100 |
| ទ្រព្យសកម្មសរុប | | 4,171,663 | 16,999,527 | 7,065,895 | 28,390,767 |
| | | | | | |
| បំណុល និងមូលធន | | | | | |
| បំណុល | | | | | |
| បំណុលផ្សេងៗ | 14 | 64,851 | 264,268 | 62,291 | 250,284 |
| ប្រាក់កម្ចី | 15 | 3,713,535 | 15,132,655 | 5,711,943 | 22,950,587 |
| បំណុលពន្ធអប្បបរមា | 13(ខ) | 970 | 3,953 | 444 | 1,784 |
| បំណុលសរុប | | 3,779,356 | 15,400,876 | 5,774,678 | 23,202,655 |
| | | | | | |
| មូលធន | | | | | |
| ដើមទុន | 16(ក) | 1,800,000 | 7,200,000 | 1,800,000 | 7,200,000 |
| ដើមទុនបន្ថែម | 16(ខ) | 500,000 | 2,000,000 | - | - |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 17 | 7,636 | 30,681 | 7,636 | 30,681 |
| ប្រាក់ខាតបង្គរ | | (1,915,329) | (7,804,966) | (516,419) | (2,074,972) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 172,936 | - | 32,403 |
| មូលធនសរុប | | 392,307 | 1,598,651 | 1,291,217 | 5,188,112 |
| បំណុល និងមូលធនសរុប | | 4,171,663 | 16,999,527 | 7,065,895 | 28,390,767 |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍លទ្ធផលលម្អិត
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់សម្គាល់ | 2019 ដុល្លារអាមេរិក | 2019 ពាន់រៀល (កំណត់សម្គាល់ 2.4) | 2018 ដុល្លារអាមេរិក | 2018 ពាន់រៀល (កំណត់សម្គាល់ 2.4) |
|---|---|---|---|---|---|
| ចំណូលពីការប្រាក់ | 18 | 750,582 | 3,041,358 | 962,574 | 3,893,612 |
| ចំណាយការប្រាក់ | 19 | (385,874) | (1,563,561) | (389,286) | (1,574,662) |
| **ចំណូលការប្រាក់សុទ្ធ** | | 364,708 | 1,477,797 | 573,288 | 2,318,950 |
| ចំណូលកម្រៃ និងជើងសារ | 20 | 11,482 | 46,525 | 9,222 | 37,303 |
| ចំណូលប្រតិបត្តិការផ្សេងៗ | | 56,325 | 228,229 | 45,548 | 184,242 |
| **ចំណូលប្រតិបត្តិការសរុប** | | 67,807 | 274,754 | 54,770 | 221,545 |
| ចំណាយទូទៅ និងរដ្ឋបាល | 21 | (720,442) | (2,919,231) | (648,008) | (2,621,192) |
| ការខាតបង់លើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ | 9 | (1,133,749) | (4,593,951) | (346,855) | (1,403,028) |
| ចំណាយពន្ធអប្បបរមា | | (8,320) | (33,713) | (10,170) | (41,138) |
| **ប្រាក់ខាតមុនដកពន្ធ** | | (1,429,996) | (5,794,344) | (376,975) | (1,524,863) |
| ឥណទានពន្ធលើប្រាក់ចំណេញ | 13(គ) | 31,086 | 125,960 | 41,090 | 166,209 |
| **ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | (1,398,910) | (5,668,384) | (335,885) | (1,358,654) |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | |
| លម្អៀងពីការប្ដូររូបិយប័ណ្ណ | | - | 78,923 | - | (21,843) |
| **សរុបលទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | | (1,398,910) | (5,589,461) | (335,885) | (1,380,497) |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | ដើមទុន | | ដើមទុនបន្ថែម | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ខាតបង្គរ | | លម្អៀងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2018 | 1,800,000 | 7,200,000 | - | - | - | - | (172,898) | (697,989) | - | 66,598 | 1,627,102 | 6,568,609 |
| លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ | | | | | | | | | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - | (335,885) | (1,358,654) | - | - | (335,885) | (1,358,654) |
| ការផ្ទេរទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | 7,636 | 30,888 | (7,636) | (30,888) | - | - | - | - |
| *លទ្ធផលលម្អិតផ្សេងៗ* | | | | | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (207) | - | 12,559 | - | (34,196) | - | (21,843) |
| **សរុបប្រាក់ខាតលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | - | - | 7,636 | 30,681 | (343,521) | (1,376,983) | - | (34,196) | (335,885) | (1,380,497) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018** | 1,800,000 | 7,200,000 | - | - | 7,636 | 30,681 | (516,419) | (2,074,972) | - | 32,402 | 1,291,217 | 5,188,112 |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន (ត)

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩

| | ដើមទុន | | ដើមទុនបន្ថែម | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ខាតបង្គរ | | លម្អៀងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ 2.4) |
| នាថ្ងៃទី1 ខែមករា ឆ្នាំ2019 | 1,800,000 | 7,200,000 | - | - | 7,636 | 30,681 | (516,419) | (2,074,972) | - | 32,402 | 1,291,217 | 5,188,112 |
| ដើមទុនបន្ថែម | - | - | 500,000 | 2,000,000 | - | - | - | - | - | - | 500,000 | 2,000,000 |
| **លទ្ធផលលម្អិតសម្រាប់ការិយបរិច្ឆេទ** | | | | | | | | | | | | |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - | (1,398,910) | (5,668,384) | - | - | (1,398,910) | (5,668,384) |
| ការផ្ទេរទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | - | - | - | - | - | - | - | - |
| លទ្ធផលលម្អិតផ្សេងៗ | | | | | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | (61,610) | - | 140,533 | - | 78,923 |
| **សរុបប្រាក់ខាតលម្អិតសម្រាប់ការិយបរិច្ឆេទ** | - | - | - | - | - | - | (1,398,910) | (5,729,994) | - | 140,533 | (1,398,910) | (5,589,461) |
| **នាថ្ងៃទី31 ខែធ្នូ ឆ្នាំ2019** | 1,800,000 | | 500,000 | 2,000,000 | 7,636 | 30,681 | (1,915,329) | (7,804,966) | - | 172,936 | 392,307 | 1,598,651 |

## របាយការណ៍លំហូរសាច់ប្រាក់
### សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់សម្គាល់ | 2019 ដុល្លារអាមេរិក | 2019 ពាន់រៀល | 2018 ដុល្លារអាមេរិក | 2018 ពាន់រៀល |
|---|---|---|---|---|---|
| | | | (កំណត់សម្គាល់ 2.4) | | (កំណត់សម្គាល់ 2.4) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ខាតសម្រាប់ការិយបរិច្ឆេទ | | (1,398,910) | (5,668,384) | (335,885) | (1,358,654) |
| *និយ័តភាពលើ៖* | | | | | |
| ចំណាយពន្ធអប្បបរមា | | 8,320 | 33,713 | 10,170 | 41,138 |
| ឥណទានពន្ធលើប្រាក់ចំណេញ | | (31,086) | (125,960) | (41,090) | (166,209) |
| រំលស់ | 11&12 | 61,494 | 249,174 | 71,099 | 287,595 |
| ចំណាយអតីតភាពការងារបុគ្គលិក | | 46,542 | 188,589 | - | - |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | | (2,045) | (8,288) | - | - |
| ការលុបចោលទ្រព្យ និងបរិក្ខារ | | - | - | 6,342 | 25,653 |
| ការខាតបង់លើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ | 9 | 1,133,749 | 4,593,951 | 346,855 | 1,403,028 |
| | | (181,936) | (737,205) | 57,491 | 232,552 |
| *បម្រែបម្រួលនៃ ៖* | | | | | |
| ឥណទានផ្តល់ដល់អតិថិជន | | 847,512 | 3,434,119 | (403,344) | (1,631,526) |
| ទ្រព្យសកម្មផ្សេងៗ | | (14,603) | (59,171) | (946) | (3,827) |
| បំណុលផ្សេងៗ | | 4,662 | 18,890 | 10,288 | 41,615 |
| សាច់ប្រាក់ដែលទទួលបានពី/(ប្រើប្រាស់ក្នុង) ប្រតិបត្តិការ | | 655,635 | 2,656,633 | (336,511) | (1,361,186) |
| ចំណាយអតីតភាពការងារបុគ្គលិកដែលបានបង់ | | (22,346) | (90,547) | - | - |
| ពន្ធអប្បបរមាដែលបានបង់ | | (7,794) | (31,581) | (9,726) | (39,342) |
| **សាច់ប្រាក់សុទ្ធទទួលបានពី/(ប្រើប្រាស់ក្នុង) សកម្មភាពប្រតិបត្តិការ** | | 625,495 | 2,534,505 | (346,237) | (1,400,528) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | 11&12 | (66,723) | (270,361) | (15,921) | (64,401) |
| ការលក់ទ្រព្យ និងបរិក្ខារ | | 45,320 | 183,637 | - | - |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ** | | (21,403) | (86,724) | (15,921) | (64,401) |

# របាយការណ៍លំហូរសាច់ប្រាក់ (ត)

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩

| | កំណត់សម្គាល់ | 2019 ដុល្លារអាមេរិក | 2019 ពាន់រៀល | 2018 ដុល្លារអាមេរិក | 2018 ពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាព** | | | (កំណត់សម្គាល់ 2.4) | | (កំណត់សម្គាល់ 2.4) |
| **ហិរញ្ញប្បទាន** | | | | | |
| ដើមទុនបន្ថែម | | 500,000 | 2,026,000 | - | - |
| ប្រាក់កម្ចី | | (2,049,706) | (8,305,408) | 750,225 | 3,034,660 |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់)/ ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | | (1,549,706) | (6,279,408) | 750,225 | 3,034,660 |
| **ការ(ថយចុះ)/កើនឡើងសុទ្ធសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | | (945,614) | (3,831,627) | 388,067 | 1,569,731 |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ | | 1,434,039 | 5,761,968 | 1,045,972 | 4,222,589 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | 59,991 | - | (30,352) |
| **សាច់ប្រាក់ និងសាច់ប្រាក់ សមមូល នាចុងការិយបរិច្ឆេទ** | 22 | 488,425 | 1,990,332 | 1,434,039 | 5,761,968 |

កំណត់សម្គាល់ដែលភ្ជាប់ជូននេះ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

## 1. ព័ត៌មានអំពីក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសហការ ភីអិលស៊ី ហៅកាត់ថា (" ក្រុមហ៊ុន ") គឺជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតត្រូវបានបង្កើតឡើង និងបានចុះបញ្ជីពាណិជ្ជកម្មលេខ Co 4361 E/2015 (ហើយបានផ្លាស់ប្តូរទៅជា 00005448) ជាមួយក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។

ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណរយៈពេលបីឆ្នាំពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី08 ខែមេសា ឆ្នាំ2016 ដើម្បីដំណើរការជាស្ថាប័ន មីក្រូហិរញ្ញវត្ថុ។ ក្រុមហ៊ុនក៏បានបន្តអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី05 ខែកក្កដា ឆ្នាំ2019។ សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ និងសេវាហិរញ្ញវត្ថុពាក់ពន្ធ័ផ្សេងទៀត ដែលមាននៅក្នុងវិសាលភាពអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការប្រែប្រួលជាសារវន្តទៅលើសកម្មភាពចម្បងរបស់ក្រុមហ៊ុននៅក្នុងការិយបរិច្ឆេទនេះទេ។

គ្រឹះស្ថានមានការិយាល័យកណ្តាលនៅផ្ទះលេខ206 ផ្លូវលេខ155 សង្កាត់ទួលទំពូងទី1 ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ គិតត្រឹមថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 ក្រុមហ៊ុនមានបុគ្គលិកសរុបចំនួន 37នាក់ (ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 មានចំនួន 34នាក់)។

## 2. មូលដ្ឋាននៃការរៀបចំ

### 2.1 របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម ("CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម")។ របាយការណ៍ហិរញ្ញវត្ថុ (សម្រាប់ឆ្នាំដែលបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 គឺជារបាយការណ៍ហិរញ្ញវត្ថុដំបូងរបស់ក្រុមហ៊ុន ដែលអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម។ មុនឆ្នាំ2019 របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ ក្រុមហ៊ុនបានអនុវត្តប្រកបដោយសង្គតិភាពក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ នៅគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។ ផលប៉ះពាល់លើរបាយការណ៍ហិរញ្ញវត្ថុ ចំពោះការផ្លាស់ប្តូរទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យមត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ទី4 ខាងក្រោម។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលក្រុមហ៊ុន និងផ្តល់សិទ្ធិផ្សាយនៅថ្ងៃទី25 ខែសីហា ឆ្នាំ2020។

### 2.2 ការិយបរិច្ឆេទហិរញ្ញវត្ថុ

ការិយបរិច្ឆេទហិរញ្ញវត្ថុរបស់ក្រុមហ៊ុនចាប់ផ្តើមនៅថ្ងៃទី01 ខែមករា និងបញ្ចប់ នៅថ្ងៃទី31 ខែធ្នូ។

### 2.3 មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើម។

### 2.4 រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល។ ក្រុមហ៊ុនធ្វើប្រតិបត្តិការ និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើមូលដ្ឋានរូបិយប័ណ្ណពីរប្រភេទ គឺប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក។ អ្នកគ្រប់គ្រងបានកំណត់ប្រាក់ដុល្លារអាមេរិក ជារូបិយប័ណ្ណគោលព្រោះវាបានឆ្លុះបញ្ចាំងពីភាពចាំបាច់នៃសេដ្ឋកិច្ច ប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោលរបស់ក្រុមហ៊ុន។ តួលេខទាំងអស់ត្រូវបានបង្គត់ឡើងចុះទៅនឹងតួលេខដែលនៅជិតបំផុតលើកលែងតែមានការបញ្ជាក់ផ្សេងទៀត។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀលត្រូវបានធ្វើឡើងដើម្បីអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជាទាក់ទងនឹងការរៀបចំ និងការកំណត់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ។ ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរទៅជាប្រាក់រៀលនាថ្ងៃនាកាលបរិច្ឆេទរាយការណ៍ហើយមូលធន ត្រូវបានប្តូរដោយប្រើ អត្រាប្តូរប្រាក់ប្រវត្តិសាស្ត្រ ។ ដោយឡែករបាយការណ៍លទ្ធផលលម្អិត និងរបាយការណ៍លំហូរសាច់ប្រាក់ គឺត្រូវបានប្តូរ ទៅជាប្រាក់រៀលដោយប្រើអត្រាប្តូរប្រាក់មធ្យមប្រចាំឆ្នាំ។ លម្អៀងលើអត្រាប្តូរប្រាក់ពីការប្តូរនេះត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងលទ្ធផលលម្អិតផ្សេងៗ។ លម្អៀងពីការប្តូររូបិយប័ណ្ណបង្គរត្រូវបានកត់ត្រាជាផ្នែកមួយនៅក្នុងរបាយការណ៍មូលធន។ គ្រប់តួលេខជាប្រាក់រៀល ត្រូវបង្គត់ជាខ្ទង់ពាន់ឡើងចុះទៅនឹងតួលេខ ដែលនៅជិតបំផុតហៅកាត់ថា ("ពាន់រៀល") លើកលែងតែមានការបញ្ជាក់ផ្សេងទៀត

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូរប្រាក់ដូចខាងក្រោមៈ

| សម្រាប់ការិយបរិច្ឆេទបញ្ចប់ | អត្រាចុងគ្រា | អត្រាមធ្យម |
|---|---|---|
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 | 1ដុល្លារ = 4,075 រៀល | 1ដុល្លារ = 4,052 រៀល |
| ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 | 1ដុល្លារ = 4,018 រៀល | 1ដុល្លារ = 4,045 រៀល |
| ថ្ងៃទី1 ខែមករា ឆ្នាំ2018 | 1ដុល្លារ = 4,037 រៀល | មិនបានប្រើប្រាស់ |

តួលេខជាប្រាក់រៀលនេះ មិនត្រូវបានយកមកបកស្រាយថា តួលេខប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់រៀល ឬនឹងត្រូវប្តូរជាប្រាក់រៀល នាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ។

### 2.5 ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ តម្រូវឲ្យអ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្មបំណុល ចំណូល និងចំណាយដែលបានរាយការណ៍។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនេះ។ការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើការប៉ាន់ស្មានគណនេយ្យត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងការិយបរិច្ឆេទដែលការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធ ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ការកែប្រែលើការប៉ាន់ស្មានគណនេយ្យត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងការិយបរិច្ឆេទ ដែលការប៉ាន់ស្មាននោះត្រូវបានកែប្រែនិងការិយបរិច្ឆេទអនាគតដែលមានផលប៉ះពាល់ដោយការកែប្រែនោះ។

ព័ត៌មាននៃការសន្មត និងការប៉ាន់ប្រមាណដែលមានភាពមិនច្បាស់លាស់ ដែលមានផលប៉ះពាល់ខ្លាំងលើការធ្វើនិយ័តកម្មក្នុងការិយបរិច្ឆេទបញ្ចប់ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 ត្រូវបានកំណត់ដូចខាងក្រោមទាក់ទងនឹងការឱនភាពនៃឧបករណ៍ហិរញ្ញវត្ថុ ដែលបានបង្ហាញនៅក្នុងគោលនយោបាយគណនេយ្យ 3.18 (ឆ) - ការកំណត់អត្តសញ្ញាណ និងការវាស់វែងនៃឱនភាព និងកំណត់សម្គាល់ 5។

## 3. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗដែលត្រូវបានអនុម័តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានកំណត់ដូចខាងក្រោម។ គោលនយោបាយទាំងនេះត្រូវបានអនុវត្តប្រកបដោយសង្គតិភាពនៅគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញលើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### 3.1 មូលដ្ឋាននៃការសរុបរួម

របាយការណ៍ហរិញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមានរបាយការណ៍ហិរញ្ញវត្ថុរបស់ទីស្នាក់ការកណ្តាល និងសាខារបស់ខ្លួន។ រាល់សមតុល្យ និងប្រតិបត្តិការអន្តរសាខាទាំងអស់ត្រូវបានលុបបំបាត់ចោល។

## 3.2 សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យធនាគារនិងប្រាក់បញ្ញើនៅធនាគារដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល ៣ខែ ឬតិចជាង និងការវិនិយោគរយៈពេលខ្លី និងដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ។សាច់ប្រាក់ និងសាច់ប្រាក់សមមូល ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើមនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## 3.3 ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើមនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## 3.4 ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា គឺរួមបញ្ចូលទាំងប្រាក់តម្កល់ធានាដើមទុន។ប្រាក់តម្កល់ធានាដើមទុន ត្រូវបានរក្សាទុកស្របតាមច្បាប់កម្ពុជាស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ហើយត្រូវបានកំណត់ដោយភាគរយនៃដើមទុនអប្បបរមាដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់ធានាដើមទុនមិនអាចផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនទេ ហេតុដូច្នេះមិនត្រូវបានចាត់ទុកថាជាផ្នែកមួយនៃសាច់ប្រាក់ និងសមមូលសាច់ប្រាក់សម្រាប់បង្ហាញក្នុងរបាយការណ៍លំហូរសាច់ប្រាក់ឡើយ។ សមតុល្យនៅធនាគារជាតិនៃកម្ពុជា ត្រូវបានគិតតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## 3.5 ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន គឺជាទ្រព្យសកម្មហិរញ្ញវត្ថុដែលការទូទាត់សងថេរ ឬអាចកំណត់បានហើយមិនមានតម្លៃសម្រង់ពីទីផ្សារសកម្ម ហើយក្រុមហ៊ុនមិនមានបំណងលក់ភ្លាមៗ ឬក្នុងរយៈពេលខ្លីណាមួយនោះទេ។ឥណទានត្រូវបានគណនាតាមតម្លៃសមស្រប បូកនឹងការចំណាយប្រតិបត្តិការដោយផ្ទាល់បន្ថែមហើយត្រូវបានគណនាជាបន្តបន្ទាប់គិតតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

## 3.6 ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗត្រូវបានកត់ត្រាតាមតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## 3.7 ទ្រព្យ និងបរិក្ខារ

### *(ក) ការទទួលស្គាល់ និងការវាស់វែង*

ផ្នែកទ្រព្យ និងបរិក្ខារត្រូវបានកត់ត្រាតាមវិធីសាស្ត្រថ្លៃដើម ដករំលស់បង្គរ និងការខាតបង់បង្គរលើ ឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន។

នៅពេលផ្នែកនៃទ្រព្យ និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសៗគ្នា ធាតុទាំងនោះត្រូវបានគេចាត់ទុកជាផ្នែកផ្សេងៗ(សមាសធាតុចម្បងៗ) នៃទ្រព្យ និងបរិក្ខារ។

ចំណេញ ឬខាតលើការលក់ចេញនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់ជាប្រាក់ចំណេញផ្សេងៗ នៅក្នុងរបាយការណ៍ចំណេញ ឬខាត។

### *(ខ) ការចំណាយបន្ទាប់*

*ថ្លៃដើមនៃការផ្លាស់ប្តូរធាតុមួយនៃទ្រព្យ និងបរិក្ខារដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលនៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុន ហើយ*

*តម្លៃរបស់វាអាចវាស់វែងបានដោយភាពជឿជាក់។ តម្លៃយោងនៃធាតុដែលបានជំនួសនោះត្រូវបានលុបចោល។ រាល់ចំណាយក្នុងការថែទាំប្រចាំថ្ងៃផ្សេងៗ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតក្នុងការិយបរិច្ឆេទដែលបានកើតឡើង។*

*(គ) រំលស់*

រំលស់នៃទ្រព្យ និងបរិក្ខារត្រូវបានកត់ត្រាក្នុងក្នុងរបាយការណ៍ចំណេញ ឬខាតតាមវិធីសាស្ត្ររំលស់ថេរតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្មនោះដូចខាងក្រោម៖

| | |
|---|---|
| ការកែលម្អអាគារ | 50% |
| គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | 50% |
| បរិក្ខារការិយាល័យ | 50% |
| បរិក្ខារកុំព្យូទ័រ | 50% |
| យានយន្ត | 25% |
| ទ្រព្យសកម្មផ្សេងៗ | 50% |

ប្រសិនបើមានការកែប្រែជាសារវន្ត ទៅលើអត្រារំលស់អាយុកាលប្រើប្រាស់តម្លៃនៅសល់នៃទ្រព្យ និងបរិក្ខារនោះរំលស់ត្រូវបានកំណត់ឡើងវិញ ដើម្បីឆ្លុះបញ្ចាំងនូវការប៉ាន់ស្មានថ្មី។

ទ្រព្យ និងបរិក្ខារដែលបានធ្វើរំលស់អស់ គឺត្រូវបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់លក់ចេញ ឬលុបចោល។

## 3.8 ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលអាចកំណត់អាយុកាលបាន ត្រូវបានដាក់ដោយឡែកពីគ្នាគឺត្រូវយកតម្លៃយោងចុងឆ្នាំដកនិងរំលស់បង្គរ និងឱនភាពខាតបង់បង្គរ។ ការរំលស់ត្រូវបានទទួលស្គាល់តាមរយៈវិធីសាស្ត្ររំលស់ថេរលើអាយុកាលប៉ាន់ស្មានរបស់ទ្រព្យសកម្មអរូបីនោះ។ វិធីសាស្ត្រដែលត្រូវបានកំណត់ពីអាយុកាលនិងរំលស់ត្រូវបានពិនិត្យឡើងវិញនៅចុងការិយបរិច្ឆេទ របាយការណ៍នីមួយៗដោយមានប្រសិទ្ធិភាពក្នុងការកំណត់នៃការប្រែប្រួល ដែលត្រូវផ្អែកលើមូលដ្ឋាននាពេលអនាគត។ ទ្រព្យសកម្មអរូបីដែលមានអាយុកាលប្រើប្រាស់មិនកំណត់ ត្រូវបានដាក់ដោយឡែកពីគ្នាគឺត្រូវយកតម្លៃយោងចុងឆ្នាំ ដកនិងឱនភាពខាតបង់បង្គរ

## 3.9 ឱនភាពនៃតម្លៃ

## ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗដើម្បីកំណត់ថាតើមានសញ្ញាណាមួយ ដែលបង្ហាញថាទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ។ ប្រសិនបើមានសញ្ញានោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្មត្រូវបានធ្វើឡើង។ តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្របដកចំណាយលើការលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់លំហូរសាច់ប្រាក់រពឹងថានឹងទទួលបាននាពេលអនាគតត្រូវបានធ្វើអប្បហារលើតម្លៃបច្ចុប្បន្នដោយប្រើអត្រាការប្រាក់មុនបង់ពន្ធដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ។ សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមទៅក្នុងក្រុមទ្រព្យសកម្មតូចៗ ដែលអាចបង្កើតជាលំហូរសាច់ប្រាក់ពីការប្រើប្រាស់ដោយមិនពឹងផ្អែកលើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬ ("ឯកតាបង្កើតសាច់ប្រាក់")។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់មានចំនួនលើសពីតម្លៃដែលអាចប្រមូលបានមកវិញ។ ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

## 3.10 ប្រាក់កម្ចី និងបំណុលផ្សេងៗ

ប្រាក់កម្ចី និងបំណុលផ្សេងៗ ត្រូវបានកត់ត្រាតាមតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## 3.11 សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្នដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈសារវន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណនៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ តម្លៃនៃអប្បហារត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញប្បទាន។

## 3.12 អត្ថប្រយោជន៍និយោជិត

### *(ក) អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី*

អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លីត្រូវបានចំណាយ នៅពេលដែលសេវាកម្មត្រូវបានផ្តល់ជូន។ ចំនួនដែលរំពឹងទុកថានឹងត្រូវចំណាយ ត្រូវបានទទួលស្គាល់ជាបំណុលប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ច តាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ក្នុងការទូទាត់ចំណាយ ដោយលទ្ធផលនៃការងារ ដែលបានបំពេញរួចមកហើយដោយបុគ្គលិក ហើយកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ស្មានដោយភាពជឿជាក់ ។

### *(ខ) អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ*

អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ គឺជាសំណងដែលត្រូវបង់ជូននិយោជិតដោយការបញ្ឈប់ពីការងារមុនពេលថ្ងៃចូលនិវត្តន៍ ឬ ការស្ម័គ្រចិត្តរបស់និយោជិត ដើម្បីទទួលយកអត្ថប្រយោជ៍ទាំងនោះជាថ្នូរនឹងការបញ្ឈប់ពីការងារដោយការស្ម័គ្រចិត្ត អត្ថប្រយោជន៍ទាំងនោះត្រូវបានទទួលស្គាល់ជាបំណុល និងជាចំណាយនៅពេលដែលក្រុមហ៊ុនមានគម្រោងបញ្ឈប់ការងារនិយោជិតជាផ្លូវការច្បាស់លាស់ ដោយមិនមានលក្ខខណ្ឌណាដែលគម្រោងនេះត្រូវដកចេញ។ ក្នុងករណីការបញ្ឈប់ដោយស្ម័គ្រចិត្តដោយនិយោជិតលើសពីតម្រូវការអត្ថប្រយោជន៍នោះត្រូវបានគណនាផ្អែកទៅលើចំនួននិយោជិតដែលរំពឹងថានឹងទទួលការស្នើសុំនេះ។ នៅពេលដែលអត្ថប្រយោជន៍ពីការបញ្ឈប់ការងារហួសកាលកំណត់លើសពី 12 ខែ បន្ទាប់ពីចុងនៃការិយបរិច្ឆេទ អត្ថប្រយោជន៍នោះត្រូវបានធ្វើអប្បហារ ទៅជាតម្លៃបច្ចុប្បន្នដោយផ្អែកលើលទ្ធផលទីផ្សារនៅចុងការិយបរិច្ឆេទ។

### *(គ) ការទូទាត់ប្រាក់អតីតភាពការងារ*

រដ្ឋមន្ត្រីនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (MoLVT) បានចេញសេចក្តីប្រកាសលេខ 443 ស្តីពីការទូទាត់ប្រាក់អតីតភាពការងារចុះថ្ងៃទី21 ខែកញ្ញា ឆ្នាំ2018 និងសារាចរលេខ 042/19 ស្តីពីការទូទាត់ប្រាក់សំណងអតីតភាពការងារមុនឆ្នាំ 2019 សម្រាប់សហគ្រាស និងស្ថាប័នក្រៅពីវិស័យវាយនភណ្ឌ វិស័យកាត់ដេរ សម្លៀកបំពាក់ និងស្បែកជើង ចុះថ្ងៃទី22 ខែមីនា ឆ្នាំ2019 ដែលតម្រូវឲ្យស្ថាប័នបង់ប្រាក់អតីតភាពការងារដល់និយោជិតដែលមានកិច្ចសន្យាគ្មានកាលកំណត់។ និយោជិតទាំងអស់ដែលបានធ្វើការមុនថ្ងៃទី01 ខែមករា ឆ្នាំ2019 និងកំពុងបន្តធ្វើការ មានសិទ្ធិទទួលបានប្រាក់

*(គ) ការទូទាត់ប្រាក់អតីតភាពការងារ (ត)*

ឈ្នួលចំនួន 6 ថ្ងៃ នៃប្រាក់ឈ្នួលជាមធ្យមរបស់ពួកគេក្នុងមួយឆ្នាំ សរុបមិនលើសពី 6 ខែហើយនឹងត្រូវបង់ជារៀងរាល់ឆ្នាំចាប់ពីខែធ្នូ ឆ្នាំ2021 ដូចខាងក្រោមនេះ៖

- 3 ថ្ងៃ ដែលធ្វើត្រូវទូទាត់នៅ ខែមិថុនា និង
- 3 ថ្ងៃ ដែលធ្វើត្រូវទូទាត់នៅ ខែធ្នូ នៃឆ្នាំនីមួយៗ

យោជិតមិនមានសិទ្ធិទទួលបានប្រាក់អតីតភាពដែលនៅសល់នៅពេលលាឈប់ ឬ បញ្ឈប់ពីការងារដោយសារការប្រព្រឹត្តមិនត្រឹមត្រូវ។

អត្ថប្រយោជន៍នៃការទូទាត់ប្រាក់អតីតភាព ត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគត ដែលគេរំពឹងថានឹងត្រូវបានធ្វើឡើងដោយក្រុមហ៊ុនទាក់ទងនឹងសេវាកម្មដែលផ្តល់ដោយនិយោជិតរហូតដល់ ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018។

ប្រកាសនេះ ក៏តម្រូវឲ្យក្រុមហ៊ុនបង់ប្រាក់អតីតភាពការងារដល់និយោជិត សម្រាប់សេវាកម្មការងារចាប់ពីឆ្នាំ2019 ដែលមានចំនួន 15 ថ្ងៃក្នុងមួយឆ្នាំនៃប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗទៀតដែល 7.5 ថ្ងៃនឹងត្រូវបង់នៅខែមិថុនា និងខែធ្នូនៃឆ្នាំនីមួយៗ។ ប្រាក់អតីតភាពការងារនេះត្រូវបានគេទទួលស្គាល់ក្នុងអំឡុងពេលនិយោជិតបំពេញសេវាកម្មដោយផ្អែកលើមូលដ្ឋានបង្គរ។

## 3.13 ភាគលាភ

ភាគលាភដែលបានប្រកាស និងអនុម័តដោយភាគទុនិករបស់ក្រុមហ៊ុន មុនពេលចុងការិយបរិច្ឆេទត្រូវបានទទួលស្គាល់ជាបំណុល និងត្រូវបានកាត់ចេញពីប្រាក់ចំណេញរក្សាទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ភាគលាភដែលបានប្រកាស និងអនុម័តដោយភាគទុនិករបស់ក្រុមហ៊ុនបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍មិនត្រូវបានទទួលស្គាល់ថាជាបំណុលទេ ប៉ុន្តែត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## 3.14 ការប្រាក់

ចំណូលការប្រាក់ និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលចំណេញឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងទុកថានឹងទូទាត់ ឬនឹងត្រូវទទួលតាមរយៈអាយុកាលរំពឹងទុករបស់ទ្រព្យសកម្មហិរញ្ញវត្ថុឬបំណុលហិរញ្ញវត្ថុ (ឬរយៈពេលខ្លីជាងប្រសិនបើសមស្រប) ទៅតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុនោះ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ក្រុមហ៊ុនត្រូវប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនមែនការបាត់បង់ឥណទាននាពេលអនាគតនោះទេ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាពរួមបញ្ចូលនូវថ្លៃប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬទទួលដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការរួមមានការចំណាយបន្ថែម ដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

## 3.15 កម្រៃ និងជើងសារ

ចំណូល និងចំណាយកម្រៃ និងជើងសារដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាពលើទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានរួមបញ្ចូលក្នុងការវាស់អត្រាការប្រាក់ប្រសិទ្ធភាព។ ចំណូលកម្រៃ និងជើងសារផ្សេងទៀត ត្រូវបានទទួល ស្គាល់នៅពេលបំពេញសេវាកម្ម។ ប្រសិនបើការសន្យាផ្តល់ឥណទានមិនត្រូវបានរំពឹងថានឹងមានលទ្ធផលក្នុងការដកប្រាក់ឥណទាននោះ កម្រៃលើការសន្យាផ្តល់ឥណទានត្រូវបានទទួលស្គាល់ ដោយផ្អែកលើមូលដ្ឋាន រំលស់ថេរទៅតាមថេរវេលានៃកិច្ចសន្យា។ ចំណាយកម្រៃផ្សេងៗ និងជើងសារ ពាក់ព័ន្ធជាចម្បងលើកម្រៃប្រតិបត្តិការ និងសេវាកម្មត្រូវបានចំណាយនៅពេលដែលសេវាកម្មត្រូវបានទទួល។

## 3.16 ភតិសន្យា

ភតិសន្យា ត្រូវបានចាត់ថ្នាក់ជាភតិសន្យាហិរញ្ញវត្ថុនៅពេលដែលលក្ខខណ្ឌនៃភតិសន្យានោះផ្ទេរជាសារវន្តនូវរាល់ហានិភ័យ សិទ្ធិអាស្រ័យផល និងកម្មសិទ្ធិនៃទ្រព្យសកម្មភតិសន្យាដល់ក្រុមហ៊ុន។ ភតិសន្យាផ្សេងទៀតត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិការ។

សិទ្ធិទៅលើទ្រព្យសកម្មក្រោមភតិសន្យាហិរញ្ញវត្ថុ ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មរបស់ក្រុមហ៊ុន តាមតម្លៃសមស្រប (ឬប្រសិនបើទាបជាងត្រូវយកតម្លៃបច្ចុប្បន្ននៃការទូទាត់អប្បបរមាលើភតិសន្យា) នៅពេលចាប់ផ្តើមនៃភតិសន្យា។ បំណុលពាក់ព័ន្ធដែលត្រូវទូទាត់សងទៅឲ្យភតិបតី ត្រូវបានកត់ត្រាក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុជាបំណុលភតិសន្យាហិរញ្ញវត្ថុ។ ការទូទាត់ភតិសន្យាត្រូវបានបែងចែករវាងចំណាយហិរញ្ញប្បទាន និងការកាត់បន្ថយបំណុលភតិសន្យា ដើម្បីទទួលបាននូវអត្រាការប្រាក់ថេរមួយ លើសមតុល្យបំណុលដែលនៅសល់។ ចំណាយហិរញ្ញប្បទាន ត្រូវបានដកចេញនៅពេលធ្វើការវាស់វែងជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផលលម្អិត។ ទ្រព្យសកម្មក្រោមភតិសន្យាហិរញ្ញវត្ថុត្រូវបានរួមបញ្ចូលក្នុងទ្រព្យ និងបរិក្ខារ ហើយត្រូវធ្វើរំលស់ និងប៉ាន់ប្រមាណឱនភាពនៃតម្លៃដូចគ្នាទៅនឹងទ្រព្យសកម្មផ្សេងទៀតរបស់ក្រុមហ៊ុនផងដែរ។

ថ្លៃឈ្នួល ដែលត្រូវទូទាត់លើភតិសន្យាប្រតិបត្តិការ ត្រូវបានកត់ត្រាជាចំណេញ ឬខាតនៅក្នុង របាយការណ៍លទ្ធផលលម្អិតតាមមូលដ្ឋានរំលស់ថេរទៅតាមថេរវេលានៃភតិសន្យា។

## 3.17 ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំនិងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផលលម្អិត លើកលែងតែក្នុងករណីដែលវាទាក់ទងទៅនឹង ធាតុណាដែលបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងទៀត។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថាត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍ និងនិយ័តភាពទាំងឡាយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ។ ពន្ធពន្យារ ត្រូវបានកំណត់ទៅលើភាពលំអៀងរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលនៅក្នុង របាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ (ហៅថាភាពលំអៀងណ្ដោះអាសន្ន)។ ពន្ធពន្យារដែលជាបំណុលត្រូវទទួលស្គាល់លើភាពលម្អៀងបណ្ដោះអាសន្ន ដែលរំពឹងថានឹងបង្កើនប្រាក់ចំណេញដែលជាប់ពន្ធនាពេលអនាគត។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានទទួលស្គាល់សម្រាប់ភាពលំអៀងបណ្ដោះអាសន្នទាំងឡាយណា ដែលរំពឹងថានឹងកាត់បន្ថយប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតរួមទាំងការខាតពន្ធ ឬឥណទានពន្ធដែលមិនទាន់បានប្រើប្រាស់ផ្សេងៗ។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានទទួលស្គាល់តាមចំនួនដែលគិតថាអាចប្រើប្រាស់បានខ្ពស់បំផុត ដោយផ្អែកលើមូលដ្ឋានប្រាក់ចំណេញជាប់ពន្ធនាពេលបច្ចុប្បន្ន ឬនាពេលអនាគត ហើយមានលទ្ធភាពខ្ពស់ក្នុងការអាចយកមកប្រើប្រាស់បាន។

តម្លៃយោងសុទ្ធនៃពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនៅរៀងរាល់កាលបរិច្ឆេទ រាយការណ៍ និងត្រូវបានធ្វើនិយ័តភាព ដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត។ និយ័តភាពទាំងនោះ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផលលម្អិតលើកលែងតែនិយ័តភាពដែលពាក់ព័ន្ធនឹងខ្ទង់ចំណូល ឬចំណាយដែលត្រូវទទួលស្គាល់ក្នុង របាយការណ៍លទ្ធផលលម្អិតផ្សេងៗដោយនិយ័តភាពនោះ ត្រូវតែទទួលស្គាល់នៅក្នុងរបាយការណ៍ លទ្ធផលលម្អិតផ្សេងៗ។

ពន្ធពន្យារ ត្រូវបានគណនាតាមអត្រាពន្ធ ដែលប្រើសម្រាប់ការគណនាប្រាក់ចំណេញជាប់ពន្ធ (ការខាតពន្ធ) ក្នុងការិយបរិច្ឆេទដែលពន្ធពន្យារជាទ្រព្យសកម្មរំពឹងថានឹងប្រើប្រាស់បាន ឬបំណុលជាពន្ធពន្យារ រំពឹងថានឹងត្រូវទូទាត់ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានកំណត់ជាអាទិ៍នានៅសម្រាប់កាលបរិច្ឆេទរាយការណ៍។

## 3.18 ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

*(ក) ការទទួលស្គាល់*

ក្រុមហ៊ុន ត្រូវបានទទួលស្គាល់ដំបូងនៅពេលដែលក្រុមហ៊ុនបានក្លាយជាភាគីនៃការផ្តល់កិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុដែលបានវាស់វែងដំបូងតាមតម្លៃសមស្របបូកនឹងចំណាយប្រតិបត្តិការដែលរួមចំណែកដោយផ្ទាល់ទៅលើការទិញលក់ទ្រព្យសកម្មហិរញ្ញវត្ថុនោះ។

*(ខ) ចំណាត់ថ្នាក់*

ក្រុមហ៊ុនត្រូវចាត់ចំណាត់ថ្នាក់ទ្រព្យហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ខ្លួនជាឧបករណ៍ហិរញ្ញវត្ថុតាម មូលដ្ឋានស្រប ដែលមានចែងក្នុងផ្នែកទី 11 នៃមូលដ្ឋានឧបករណ៍ហិរញ្ញវត្ថុ។

*(គ) ការឈប់ទទួលស្គាល់*

ក្រុមហ៊ុន ឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលបានសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មនោះផុតកំណត់ ឬក្រុមហ៊ុនបានផ្ទេរសិទ្ធិក្នុងការទទួលបានសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការដែលហានិភ័យ និងផលចំណេញនៃភាពជាម្ចាស់កម្មសិទ្ធិលើទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានផ្ទេរចេញ ទាំងមិនផ្ទេរចេញឬទាំងមិនរក្សាហានិភ័យ និងផលចំណេញនៃភាពជាម្ចាស់កម្មសិទ្ធិលើទ្រព្យសកម្មហិរញ្ញវត្ថុ និងមិនរក្សាការគ្រប់គ្រងទៅលើទ្រព្យសកម្មដែលផ្ទេរចេញ។

ក្រុមហ៊ុនមិនទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលកាតព្វកិច្ចកិច្ចសន្យាត្រូវបានរំសាយ ឬលុបចោល ឬផុតកំណត់។

*(ឃ) ការកាត់កង*

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយតម្លៃយោងសុទ្ធត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលក្រុមហ៊ុនមានសិទ្ធតាមផ្លូវច្បាប់ដើម្បីទូទាត់ និងមានបំណងធ្វើការទូទាត់លើមូលដ្ឋានតម្លៃសុទ្ធឬដើម្បីទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលជាប្រចាំ។

*(ង) ការវាស់វែងរំលស់ថ្លៃដើម*

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងទៅតាមរំលស់ថ្លៃដើម ដែលបានកត់ត្រាតាមថ្លៃដើមដំបូងដករំលស់ថ្លៃដើម បូក ឬដកចំនួនបង្គរដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៃភាពខុសគ្នារវាងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ដំបូង និងចំនួនដល់កាលកំណត់ដកនឹងតម្លៃឱនភាព។

*(ច) ការវាស់វែងតម្លៃសមស្រប*

តម្លៃសមស្រប គឺជាតម្លៃដែលត្រូវបានទទួលដើម្បីលក់ទ្រព្យសកម្ម ឬបង់ដើម្បីផ្ទេរបំណុលក្នុងប្រតិបត្តិការ រវាងអ្នកចូលរួមទីផ្សារនៅកាលបរិច្ឆេទនៃការវាស់វែងដើមឬក្នុងករណីដែលមិនមាន អត្ថប្រយោជន៍ទីផ្សារច្រើនបំផុតដែលក្រុមហ៊ុនទទួលបាននៅកាលបរិច្ឆេទនោះ។ តម្លៃសមស្របនៃបំណុលឆ្លុះបញ្ចាំងពីហានិភ័យមិនដំណើរការរបស់វា។

ក្រុមហ៊ុនអាចវាស់វែងតម្លៃសមស្រប ដោយប្រើប្រាស់តម្លៃប៉ាន់ស្មានដែលបានដកស្រង់ពីទីផ្សារសកម្មសម្រាប់ឧបករណ៍ហិរញ្ញវត្ថុនោះ។ ទីផ្សារត្រូវបានចាត់ទុកថាសកម្ម ប្រសិនបើប្រតិបត្តិការសម្រាប់ទ្រព្យសកម្ម ឬបំណុលត្រូវកើតឡើងដោយមានបរិមាណគ្រប់គ្រាន់ ដើម្បីផ្តល់ព័ត៌មានអំពីតម្លៃជាប្រចាំ។ ប្រសិនបើមិនមានតម្លៃប៉ាន់ស្មានពីទីផ្សារសកម្មទេនោះ ក្រុមហ៊ុនអាចប្រើបច្ចេកទេសវាយតម្លៃដែលបង្កើនការប្រើប្រាស់ធាតុចូលដែលអាចសង្កេតបាន និងកាត់បន្ថយការប្រើប្រាស់ធាតុចូលដែលមិនអាចគ្រប់គ្រងបាន។ បច្ចេកទេសវាយតម្លៃដែលត្រូវបានជ្រើសរើសរួមបញ្ចូលកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារពិចារណាលើការកំណត់តម្លៃប្រតិបត្តិការ។

ភស្តុតាងល្អបំផុតនៃតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ ដែលជាការទទួលស្គាល់ថ្លៃដើមដំបូង គឺជាថ្លៃប្រតិបត្តិការធម្មតា ឧទាហរណ៍ ពិចារណាតម្លៃសមស្របដែលបានផ្តល់ឲ្យ ឬទទួលបាន។ ប្រសិនបើក្រុមហ៊ុនកំណត់ថាតម្លៃសមស្របតាមថ្លៃដើមដំបូងដែលខុសគ្នាពីតម្លៃប្រតិបត្តិការ និងតម្លៃសមស្របដែលមានការបញ្ជាក់ មិនថាតាមតម្លៃទីផ្សារសកម្មសម្រាប់កំណត់ទ្រព្យសកម្ម ឬបំណុលដែលដូចគ្នា និងមិនផ្អែកលើបច្ចេកទេសវាយតម្លៃ ដែលប្រើប្រាស់ទិន្នន័យពីទីផ្សារដែលអាចអង្កេតបាន។ បន្ទាប់មកឧបករណ៍ហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្របកែសម្រួល ដើម្បីពន្យារភាពខុសគ្នារវាងតម្លៃសមស្របនៃការទទួលស្គាល់ដំបូង និងតម្លៃប្រតិបត្តិការ។

បន្ទាប់មកភាពខុសគ្នានោះត្រូវបានទទួលស្គាល់ជាចំណេញ ឬ ខាតដោយផ្អែកលើមូលដ្ឋានសមស្របនៃអាយុកាលឧបករណ៍ ប៉ុន្តែមិនយូរជាងពេលដែលធ្វើការវាយតម្លៃ គឺត្រូវបានគាំទ្រទាំងស្រុងដោយទិន្នន័យ ទីផ្សារដែលអាចសង្កេតបានឬប្រតិបត្តិការត្រូវបានបិទ។

ក្រុមហ៊ុន ទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្រប នៅចុងបញ្ចប់នៃការិយបរិច្ឆេទ រាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

*(ឆ) ការកំណត់អត្តសញ្ញាណ និងការវាស់វែងនៃឱនភាព*

**ភស្តុតាងដែលបញ្ជាក់ពីឱនភាព**

នាកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនវាយតម្លៃ ថាតើមានភស្តុតាងជាក់ស្តែងនៃទ្រព្យសកម្ម ហិរញ្ញវត្ថុដែលត្រូវបានវាស់វែងដោយថ្លៃដើម ឬរំលស់ឬទេ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានកាត់បន្ថយនៅពេលមានភស្តុតាងបង្ហាញថាព្រឹត្តិការណ៍ខាតបង់បានកើតឡើង បន្ទាប់ពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម ហើយព្រឹត្តិការណ៍ខាតបង់មានផលប៉ះពាល់ដល់លំហូរសាច់ប្រាក់នាពេលអនាគតនៃទ្រព្យសកម្មដែលអាចប៉ាន់ស្មានបាន។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មមានឱនភាព រួមមាន៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាសារវន្តរបស់អ្នកខ្ចី ឬអ្នកបោះផ្សាយ
- ភាពមិនទៀងទាត់ ឬការលុបចោលដោយអ្នកខ្ចី
- ការរៀបចំឡើងវិញនូវលក្ខខណ្ឌទូទាត់សង ដែលក្រុមហ៊ុនមិនបានរំពឹងទុក
- សញ្ញាណបង្ហាញថាកូនបំណុល នឹងជួបប្រទះការក្ស័យធន
- ការបាត់បង់នៃទីផ្សារសកម្មសម្រាប់មូលប័ត្រ ឬ
- ទិន្នន័យដែលអាចអង្កេតបានទាក់ទងទៅនឹងក្រុមនៃទ្រព្យសកម្ម ដូចជាការផ្លាស់ប្តូរអវិជ្ជមាននៃស្ថានភាពទូទាត់របស់កូនបំណុល ឬអ្នកបោះផ្សាយនៅក្នុងក្រុម ឬលក្ខខណ្ឌសេដ្ឋកិច្ចដែលទាក់ទងនឹងលំនាំដើមនៅក្នុងក្រុម។

**ការវាយតម្លៃទោល និងជាក្រុម**

រាល់ទ្រព្យសកម្មសំខាន់ៗ ត្រូវបានវាយតម្លៃផ្សេងៗពីគ្នាចំពោះឱនភាព។

ជាពិសេសទ្រព្យសកម្ម ដែលត្រូវបានគេរកឃើញថាមិនមានឱនភាពត្រូវបានវាយតម្លៃរួមគ្នាសម្រាប់ ឱនភាពដែលបានកើតឡើងប៉ុន្តែមិនទាន់បានកំណត់បញ្ជាក់នៅឡើយ។

សមាសធាតុនីមួយៗនៃសំវិធានធននៃឱនភាព ត្រូវអនុវត្តទៅលើទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបាន វាយតម្លៃចំពោះឱនភាពក្នុងលក្ខណៈទោលហើយត្រូវបានគេរកឃើញថាមានឱនភាពក្នុងលក្ខណៈទោលដោយផ្អែកលើការប៉ាន់ស្មានដ៏ប្រសើរបំផុតរបស់អ្នកគ្រប់គ្រង លើតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ដែលរំពឹងថានឹងទទួលបាន។ ក្នុងការប៉ាន់ស្មានលំហូរសាច់ប្រាក់ទាំងនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យអំពីស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុលនិងតម្លៃដែលអាចកំណត់បាននៃទ្រព្យបញ្ចាំណាមួយ។ ឱនភាពនៃទ្រព្យសកម្មនីមួយៗ ត្រូវបានវាយតម្លៃលើគុណប្រយោជន៍របស់វា ហើយយុទ្ធសាស្ត្រសាកល្បងនិងការប៉ាន់ប្រមាណលំហូរសាច់ប្រាក់ដែលអាចរកបានមកវិញ ត្រូវបានអនុម័តដោយអ្នកគ្រប់គ្រងឯករាជ្យ។

សមាសធាតុនៃឱនភាពនៃតម្លៃជាក្រុមត្រូវបានបង្កើតឡើងសម្រាប់៖

- ក្រុមនៃប្រាក់កម្ចីមានលក្ខណៈដូចគ្នាដែលមិនត្រូវបានចាត់ទុកថាមានលក្ខណៈទោលសារវន្ត និង
- ក្រុមនៃទ្រព្យសកម្មដែលមានលក្ខណៈទោលសារវន្ត ប៉ុន្តែមិនត្រូវបានគេរកឃើញថាមានឱនភាព

សំវិធានធនសម្រាប់ក្រុមនៃប្រាក់កម្ចី ដែលមានលក្ខណៈដូចគ្នាត្រូវបានបង្កើតឡើងដោយប្រើវិធីសាស្រ្តស្ថិតិ ដូចជាវិធីសាស្រ្តអត្រាបន្ត ឬសម្រាប់ផលប័ត្រតូចៗ ដែលមានព័ត៌មានមិនគ្រប់គ្រាន់ ឬរូបមន្តផ្អែកលើបទពិសោធន៍អត្រាការខាតបង់យោងតាមនិន្នាការពីមុន។

ក្នុងការវាយតម្លៃឥណទានសំវិធានធនលើការបាត់បង់ជាក្រុម គណៈគ្រប់គ្រងពិចារណាលើកត្តាដូចជា គុណភាពឥណទានទំហំផលប័ត្រ ការប្រមូលផ្តុំ និងកត្តាសេដ្ឋកិច្ច។ ដើម្បីប៉ាន់ប្រមាណនូវសំវិធានធនចាំបាច់ ត្រូវបានបង្កើតឡើងដើម្បីកំណត់ពីរបៀបការខាតបង់ជាយថាផល ត្រូវបានយកគំរូតាមនិងតម្រូវបញ្ចូលប៉ារ៉ាម៉ែត្រ ដែលផ្អែកលើបទពិសោធន៍ពីមុន និងស្ថានភាពសេដ្ឋកិច្ច បច្ចុប្បន្ន។ ភាពត្រឹមត្រូវនៃសំវិធានធនអាស្រ័យលើការសន្មតម៉ូដែល និងប៉ារ៉ាម៉ែត្រដែលត្រូវបានប្រើក្នុងការកំណត់សំវិធានធនជាក្រុម។

➤ ការវាស់វែង

ការវាស់វែងតាមវិធីរំលស់ថ្លៃដើមលើការខាតបង់នៃឱនភាពទ្រព្យសកម្ម ត្រូវបានគណនាពីភាពខុសគ្នារវាងតម្លៃយោងនិងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគត ដែលត្រូវបានកាត់បន្ថយតាមអត្រាការប្រាក់ប្រសិទ្ធភាពលើតម្លៃដើមទ្រព្យសកម្ម។

➤ ការកែប្រែនៃឱនភាព និងការលុបចោល

ប្រសិនបើក្នុងរយៈពេលជាបន្តបន្ទាប់សំវិធានធនលើឱនភាពមានការថយចុះ ហើយការថយចុះអាចទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងបន្ទាប់ពីឱនភាពត្រូវបានទទួលស្គាល់ ក្រុមហ៊ុនត្រូវកែប្រែការខាតបង់នៃតម្លៃឱនភាពដែលបានទទួលស្គាល់ពីមុនដោយផ្ទាល់ ឬដោយការនិយ័តភាពសំវិធានធន។

ក្រុមហ៊ុនលុបចោលបំណុល ឬបំណុលវិនិយោគទាំងផ្នែកខ្លះ ឬទាំងអស់ដែលពាក់ព័ន្ធនឹងសំវិធានធនលើឱនភាពតម្លៃ នៅពេលដែលអ្នកគ្រប់គ្រងកំណត់ថាមិនមានលទ្ធភាពមិនអាច ប្រមូលមកវិញ។

## 3.19 ទុនបម្រុងតាមបទប្បញ្ញត្តិ

ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីប្រកាសលេខ ធ7-017-344 ចុះថ្ងៃទី1 ខែធ្នូ ឆ្នាំ2017 ស្តីពីការដាក់ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមផែរមិន និងសារាចរលេខ ធ7-018-001 ចុះថ្ងៃទី16 ខែកុម្ភៈ ឆ្នាំ2018 ស្តីពីកាអនុវត្តប្រកាសស្តីពីការផ្តល់ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមផែរមិន ដែលតម្រូវឲ្យគ្រឹះស្ថានធនាគារនិងស្ថាប័នហិរញ្ញវត្ថុទាំងអស់ ("ស្ថាប័ន") អនុវត្តការវាស់វែង ការធ្វើសំវិធានធនឥណទាន ដោយផ្អែកតាមអត្រាហានិភ័យឥណទានថ្មីដូចខាងក្រោម៖

| **ចំណាត់ថ្នាក់** | **ចំនួនថ្ងៃដែលផុតកំណត់** | **សំវិធានធន** |
|---|---|---|
| ឥណទានរយៈពេលខ្លី (តិចជាង1ឆ្នាំ) | | |
| ស្តង់ដារ | ពី 0 ទៅ 14 ថ្ងៃ | 1% |
| ឃ្លាំមើល | ពី 15 ទៅ 29 ថ្ងៃ | 3% |
| ក្រោមស្តង់ដារ | ពី 30 ទៅ 59 ថ្ងៃ | 20% |
| ជាប់សង្ស័យ | ពី 60 ទៅ 89 ថ្ងៃ | 50% |
| បាត់បង់ | 90 ថ្ងៃ ឬច្រើនជាង | 100% |

ឥណទានរយៈពេលវែង(លើសពី1ឆ្នាំ)

| | | |
|---|---|---|
| ស្តង់ដារ | ពី 0 ទៅ 29 ថ្ងៃ | 1% |
| ឃ្លាំមើល | ពី 30 ទៅ 89 ថ្ងៃ | 3% |
| ក្រោមស្តង់ដារ | ពី 90 ទៅ 179 ថ្ងៃ | 20% |
| ជាប់សង្ស័យ | ពី 180 ទៅ 359 ថ្ងៃ | 50% |
| បាត់បង់ | 360 ថ្ងៃ ឬច្រើនជាង | 100% |

យោងតាមមាត្រាទី 73 ក្រុមហ៊ុនត្រូវតែធ្វើការប្រៀបធៀបសំវិធានធនគណនាស្របតាមបទប្បញ្ញត្តិនៃធនាគារជាតិនៃកម្ពុជា និងសំវិធានធនគណនាតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម៖

(ក) ប្រសិនបើទុនបម្រុងតាមបទប្បញ្ញត្តិទាបជាង ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនដែលបានគណនាស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និង

(ខ) ប្រសិនបើទុនបម្រុងតាមបទប្បញ្ញត្តិធំជាង ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនដែលបានគណនាស្របតាមតាមស្តង់ដារដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងផ្ទេរភាពខុសគ្នាពីប្រាក់ចំណេញរក្សាទុកទៅក្នុងគណនីទុនបម្រុងក្នុងគណនីមូលធន។

### 3.20 សម្ព័ន្ធញាតិ

សហគ្រាស និងបុគ្គលដែលទាក់ទងផ្ទាល់ ឬមិនផ្ទាល់តាមរយៈអន្តរការីមួយ ឬច្រើន ឬត្រូវបានគ្រប់គ្រង ក្រោមការគ្រប់គ្រងរួមជាមួយក្រុមហ៊ុ ន តែមួយ ក្រុមហ៊ុនសម្ព័ន្ធ និងក្រុមហ៊ុនសម្ព័ន្ធផ្សេងទៀតដែលជាភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន។ សហការី និងបុគ្គលដែលទាក់ទងផ្ទាល់ ឬមិនផ្ទាល់ត្រូវធ្វើតាមអំណាចនៃការបោះឆ្នោតរបស់ក្រុមហ៊ុនដែលផ្តល់ឲ្យពួកគេមានឥទ្ធិពលយ៉ាងសំខាន់មកលើសហគ្រាស គណៈគ្រប់គ្រងសំខាន់ៗរួមមាន នាយក និងបុគ្គលិកក្រុមហ៊ុន និងសមាជិកជិតស្និទ្ធជាមួយក្រុមគ្រួសាររបស់បុគ្គលនោះ ក៏ដូចជាក្រុមហ៊ុនដែលសហការជាមួយបុគ្គលទាំងនេះ ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធផងដែរ។

## 4. ការផ្លាស់ប្តូរទៅស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRS") សម្រាប់សហគ្រាសធុនតូច និងមធ្យម

នៅថ្ងៃទី28 ខែសីហា ឆ្នាំ2009 ក្រុមប្រឹក្សាគណនេយ្យជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ("ក្រុមប្រឹក្សាគណនេយ្យជាតិ" ) បានប្រកាសអនុម័តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាដែលផ្អែកលើស្តង់ដារទាំងអស់ដែលបានចេញផ្សាយដោយស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ("IASB") រួមបញ្ចូលទាំងការបកស្រាយ និងការកែប្រែ។ អង្គភាពគណនេយ្យសាធារណៈចាំបាច់ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដោយអនុលោមតាមស្តង់ដារCIFRS សម្រាប់បញ្ជីគណនេយ្យចាប់ផ្តើម ឬបន្ទាប់ពីថ្ងៃទី1ខែមករាឆ្នាំ2012។

សារាចរលេខ 058 MEF.NAC ចុះថ្ងៃទី24 ខែមីនា ឆ្នាំ2016 ចេញដោយក្រុមប្រឹក្សាគណនេយ្យជាតិនៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុញ្ញាតឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុពន្យារពេលអនុវត្តស្តង់ដារCIFRS រហូតដល់ការិយបរិច្ឆេទចាប់ផ្តើម ឬក៏បន្ទាប់ពីថ្ងៃទី1 ខែមករា ឆ្នាំ2019។

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2019 គឺជារបាយការណ៍ហិរញ្ញវត្ថុដំបូងរបស់ក្រុមហ៊ុន ដែលអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃ កម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម។ កាលបរិច្ឆេទនៃការផ្លាស់ប្តូររបស់ក្រុមហ៊ុនទៅតាមស្តង់ដារ CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម គឺនៅថ្ងៃទី01 ខែមករា ឆ្នាំ2018។ របាយការណ៍ចុងក្រោយត្រូវបានរៀបចំស្របតាមស្តង់ដារគណនេយ្យកម្ពុជា ("CAS") សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018។

ការផ្លាស់ប្តូរការអនុវត្តតាមស្តង់ដារ CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យមបានបណ្តាលឲ្យមានការផ្លាស់ប្តូរគោលការណ៍គណនេយ្យរបស់ក្រុមហ៊ុនមួយចំនួនចំពោះបើប្រៀបធៀបទៅនឹងការអនុវត្តតាមស្តង់ដារគណនេយ្យកម្ពុជា។ កំណត់សម្គាល់នេះចំពោះរបាយការណ៍ហិរញ្ញវត្ថុគឺ ពន្យល់អំពីភាពខុសប្លែកគ្នារវាងរបាយការណ៍ចំណេញ ឬខាតតាមការអនុវត្តន៍ស្តង់ដារគណនេយ្យកម្ពុជា និងតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យមសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី31 ខែធ្នូ ឆ្នាំ2018។ (ឧទាហរណ៍៖ ការប្រៀបធៀបព័ត៌មាន) ក៏ដូចជាភាពខុសគ្នារវាងការបង្ហាញមូលធនតាមស្តង់ដារ CAS និងតាមស្តង់ដារ CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យមនៅកាលបរិច្ឆេទនាថ្ងៃទី1 ខែមករា ឆ្នាំ2018 និងនាថ្ងៃទី31 ខែធ្នូ ឆ្នាំ2018។ វាក៏ពិពណ៌នាផងដែរនូវរាល់ការផ្លាស់ប្តូរ ដែលចាំបាច់នៅក្នុងគោលការណ៍គណនេយ្យដែលបានអនុម័តជាលើកដំបូង តាម CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម។

នៅក្នុងតារាងខាងក្រោម មូលធនដែលបានកំណត់តាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យមត្រូវបានផ្ទៀងផ្ទាត់ ជាមួយមូលធនដែលបានកំណត់តាមស្តង់ដារ គណនេយ្យកម្ពុជា ("CAS") នៅថ្ងៃទី01 ខែមករា ឆ្នាំ2018 (កាលបរិច្ឆេទនៃការផ្លាស់ប្តូរទៅតាមស្តង់ដារ CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម) និង ថ្ងៃទី31 ខែធ្នូ ឆ្នាំ2018 (កាលបរិច្ឆេទបញ្ចប់ចុងក្រោយសម្រាប់របាយការណ៍ហិរញ្ញវត្ថុ ដែលបានរៀបចំស្តង់ដារតាម CAS)។

(ក) **ការផ្ទៀងផ្ទាត់មូលធននាថ្ងៃទី1 ខែមករា ឆ្នាំ2018**

| | | **នាថ្ងៃទី01 ខែមករា ឆ្នាំ2018** | | | |
|---|---|---|---|---|---|
| | **កំនត់សម្គាល់** | **តាមស្តង់ដារ CAS** | **ផលប៉ះពាល់នៃការផ្លាស់ប្តូរ** | **តាមស្តង់ដារ CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម** | |
| | | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| **ទ្រព្យសកម្ម** | | | | | (កំណត់សម្គាល់ 2.4) |
| សាច់ប្រាក់ក្នុងដៃ | | 11,735 | - | 11,735 | 47,374 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | | 100,318 | - | 100,318 | 404,984 |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ | | 1,023,919 | - | 1,023,919 | 4,133,561 |
| ឥណទានផ្តល់ដល់អតិថិជនសុទ្ធ | 4.1 | 5,251,486 | 10,169 | 5,261,655 | 21,241,301 |
| ទ្រព្យសកម្មផ្សេងៗ | 4.2 | 73,219 | (50,571) | 22,648 | 91,430 |
| ទ្រព្យ និងបរិក្ខារ | | 219,273 | - | 219,273 | 885,205 |
| ទ្រព្យសកម្មអរូបី | | 1,275 | - | 1,275 | 5,147 |
| **ទ្រព្យសកម្មសរុប** | | 6,681,225 | (40,402) | 6,640,823 | 26,809,002 |

| | | នាថ្ងៃទី01 ខែមករា ឆ្នាំ2018 | | | |
|---|---|---|---|---|---|
